ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរ**
**នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"**
**សាធារណៈ**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩**
**សវនាការលើកទី៣៤**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc Lavegne)*
លោក ធូ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍
*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង
លោក ឌុច ផារី
លោកស្រី សែ កុលវុឌ្ឍី
លោក ម៉ាតូ គ្រីស្ពារ *(Mr. Matteo Crippa)*
កញ្ញា ណាថាក់ វិចស៊ែល
*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក យ៉េតចរិយា

លោក វីលៀម ស្មីត *(Mr. William Smith)*

លោក ពេជ្រ សម្បត្តិ

លោក ហ្សាឆិរី ឡាំប៉ែល *(Mr.Zachery LAMPEL)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**ជនជាប់ចោទ៖**

លោក កាំង ហ្គេក អ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក គីម ម៉េងឃី

កញ្ញា ទី ស្រ៊ីនណា

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោកស្រី ចេស្ស៊ីកា ហ្វីណែល

*(Ms. Jessica FINELLE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សី** ៖ ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច

សួរដោយ លោក យ៉េត ចរិយា ផ្តើមពី......ទំព័រ ១
សួរដោយ លោក វីលៀម ស្មីត ផ្តើមពី......ទំព័រ ៨
សួរដោយ កញ្ញា ទី ស្រ៊ីនណា ផ្តើមពី......ទំព័រ១៧
សួរដោយ លោក អាឡាំង វ៉ែនណឺ ផ្តើមពី......ទំព័រ២០
សួរដោយ លោកស្រី ស៊ីលឃី ស្ទួតហ្សែនស្គី ផ្តើមពី......ទំព័រ២៣
សួរដោយ កញ្ញា ម៉ុច សុវណ្ណារី ផ្តើមពី......ទំព័រ២៧
សួរដោយ លោក គីម ម៉េងឃី ផ្តើមពី......ទំព័រ២៩
សួរដោយ លោក ហុង គីមសួន ផ្តើមពី......ទំព័រ៣២
សួរដោយ លោក ការ សាវុត្ថ ផ្តើមពី......ទំព័រ៣៨

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក ម៉ុច សុវណ្ណារី | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោក វីលៀម ស្មីត | អង់គ្លេស |
| លោក អាឡាំងវែនណឺ | អង់គ្លេស |
| លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ-បារាំង |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |
| លោក យ៉េត ចរិយា | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:០៤:២៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលលើអង្គហេតុ ការបង្កើត និងប្រតិបត្តិការនៃមន្ទីរអប់រំកែប្រែសាជាថ្មីព្រៃស ឬមន្ទីរស-២៤ ។ មុននឹងប្រគល់វេទិកានេះជូនទៅភាគី ដើម្បីធ្វើការសួរដេញដោលចំពោះជនជាប់ចោទនូវអង្គហេតុដែលបានជម្រាបជូននេះ អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគីថា អង្គជនុំជម្រះសាលាដំបូងមានបំណងដកសាក្សីមួយរូបទៀត គឺ KW-24 ដោយហេតុសក្ខីកម្មនានា អង្គជំនុំជម្រះកត់សម្គាល់ឃើញថាមានចំនួនច្រើនហើយ ។ ម្យ៉ាងទៀតក៏មានចម្លើយនៃសាក្សីឯទៀតដែលយើងនឹងកោះហៅគាត់មកធ្វើសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនោះ ក៏មានខ្លឹមសារប្រហាក់ប្រហែលគ្នានឹងសាក្សីKW-24 ដែរ ដោយអង្គជំនុំជម្រះគ្រាន់តែលើកយកបញ្ហានេះមកអាននៅក្នុងករណីសមស្រប ដូចដែលយើងបានពិភាក្សាគ្នាកាលពីថ្ងៃមុន ។ ហើយជម្រាបផងដែរបញ្ហានេះ គូភាគីទាំងអស់មិនចាំបាច់ទាន់ផ្តល់នូវមតិយោបល់របស់ខ្លួននាពេលនេះទេ គឺគ្រាន់តែជម្រាបជូនដំណឹងអ៊ីចឹង ។ ហើយការផ្តល់មតិយោបល់ កត់សម្គាល់ពាក់ព័ន្ធជាមួយនឹងការស្នើសុំដកនូវសាក្សី KW-24 នេះ គឺធ្វើនៅថ្ងៃច័ន្ទ នៅព្រឹកថ្ងៃច័ន្ទ ។ អ៊ីចឹង សូមជ្រាប ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទមកកាន់ឈើរាងរង្វង់ក្រចកសេះនៅទីនោះ ។

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកានេះជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីធ្វើការសួរដេញដោលចំពោះជនជាប់ចោទនូវអង្គហេតុដែលយើងបានកំណត់អម្បាញ់មិញនេះ គឺអង្គហេតុនៃការបង្កើត និងប្រតិបត្តិការនៃមន្ទីរព្រៃស ឬក៏ ស-២៤ ។ សូមអញ្ជើញ ។

**សួរដោយ លោក យ៉េត ចរិយា៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមានសំណួរមួយចំនួន ដើម្បីសួរទៅជនជាប់ចោទ ។

**ស៖** សំណួរ ឌុច សូមលោកបញ្ជាក់មើល តើព្រៃស ឬស-២៤ មានលក្ខណៈខុសនឹងសហករណ៍មូលដ្ឋានយ៉ាងម៉េចខ្លះ?

[០៩:០៨:៤១]

**ជនជាប់ចោទ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ស-២៤ វាមានលក្ខណៈដូចសហករណ៍មូលដ្ឋានក្នុងរឿងមួយចំនួន គឺសំខាន់ គឺសិទ្ធិក្នុងបញ្ហារស់នៅ ដូចគ្នា ។ មិនមានអចិន្ត្រៃយ៍សម្រេច ឬលេខាភូមិភាគសម្រេចផ្ទាល់ៗករណីគ្រប់ករណីទេ នេះដែលដូចគ្នា ។ ក៏ប៉ុន្តែ មិនដូចគ្នាត្រង់ស-២៤ ប្រមូលផ្តុំមនុស្សដែលមានស្លាកស្នាមស្រាប់រួចទៅហើយ ។ ឯចំណែក សហករណ៍មូលដ្ឋានប្រមូលផ្តុំមនុស្សទៅតាមវណ្ណៈដែលគេមិនជឿទុកចិត្ត ។ ខុសគ្នាត្រង់ហ្នឹង ។

ទីពីរ ដែលខុសគ្នា នៅស-២៤ ភាគច្រើនជាអតីតយុទ្ធជនយុទ្ធនារីរបស់បក្សកុម្មុយនីស្តកម្ពុជា មិនសូវមានគ្រួសារចូលទៅនៅហ្នឹងប៉ុន្មានពេកទេ ។ ឯចំណែកសហករណ៍មូលដ្ឋាន ភាគច្រើនគឺជាមនុស្សដែលមានគ្រួសារ មានប្តី មានប្រពន្ធ មានកូន និងជីដូន ជីតា ម៉ែឪអីនៅហ្នឹង ជុំគ្នា ។ ដូច្នេះ ខុសអ៊ីចឹង ។ សូមជម្រាបប៉ុណ្ណឹង ។

[០៩:១០:០៧]

**ស៖** សំណួរបន្ត តើរចនាសម្ព័ន្ធស-២៤ មានបង្កើតក្រុមឈ្លបយកការណ៍ពីសមាសភាពទាំងនោះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ការងារនេះវាជាសាខាមួយរបស់បុគ្គលិកមន្ទីរស-២១ ដែលធ្វើការនៅហ្នឹង ។ យប់ឡើងមានមួយចំនួនត្រូវប្រធានចាត់តាំងឲ្យទៅយកការណ៍ពីពួកសមាសភាព លបស្តាប់ លបតាមដាន លបអី ដូច្នេះមាន ។ ប៉ុន្តែ គេចាត់តាំងយ៉ាងម៉េច គ្រាន់តែខ្ញុំមិនជាក់ស្តែងអ្នកណាប្រធាន អ្នកណាអីចាត់តាំងពីម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មាន ខ្ញុំអត់ច្បាស់ទេ ។ មាន គឺមាន ។

**ស៖** ពេលយកការណ៍បានពីសមាសភាពទាំងនោះ គេធ្វើអ្វីទៅលើដែលអ្នកមានកំហុសនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! អ្នកដែលយកការណ៍បាន ជាគោលការណ៍ គេរាយការណ៍តាមខ្សែរយៈមកដល់មិត្តហ៊ុយៗ នេះជាដំណាក់មួយ ។ វាទាល់តែមានភស្តុតាង ឬក៏បាតុភាពជាក់ស្តែងថាឃើញប្រុងរត់ អាហ្នឹងបានៗអ្នកយកការណ៍ឃើញរត់ចេញ បានៗអ្នកយកការណ៍គេចាប់។ អាហ្នឹងដែលគេហៅថា ភស្តុតាងជាក់ស្តែងនឹងភ្នែក បាតុភាពល្មើសជាក់ស្តែងនឹងភ្នែកគេចាប់ ។ ក៏ប៉ុន្តែជាទូទៅគ្រាន់តែឮសម្តីពាក្យយ៉ាងនេះយ៉ាងនោះ គេរាយការណ៍តាមខ្សែរយៈមកដល់មិត្តហ៊ុយ ។ រយៈកាលណាមួយជាកំណត់ ឬមានហេតុអីច្បាស់លាស់ជាកំណត់មិត្តហ៊ុយ មកជួបមិត្តហ៊ី នេះគឺដំណើរការ

អ៊ីចឹង ។ ទាល់តែមិត្តហ៊ី សម្រេចជាមួយគ្នាមិត្តហ៊ុយ បានៗគេចាត់ចែងបាន ។

[០៩:១២:១២]

**ស៖** មិត្តហ៊ី និងមិត្តហ៊ុយ មានរាយការណ៍ឲ្យលោកទេ?

**ឆ៖** ជាគោលការណ៍ នេះកិច្ចដំណើរការដែលមានបន្តតាំងពីសម័យមន្ទីរនគរបាលកងពល ៧០៣ មកម្ល៉េះ ទាល់តែករណីពិសេសខ្លះ បានៗគេរាយការណ៍ឲ្យខ្ញុំ ។

**ស៖** សូមលោកបញ្ជាក់ពីករណីពិសេសនោះយ៉ាងម៉េចខ្លះ ដែលហៅថា ករណីពិសេសនោះ?

**ឆ៖** ដែលហៅថា ករណីពិសេស ឧទាហរណ៍ ដូចជារឿងមិត្តណាន ឈ្មោះដើម សឹម មែល មានបាតុភាពបណ្តើរៗហួរហែ ត្រូវតែរាយការណ៍ដល់ខ្ញុំ ។ ព្រោះអី? ព្រោះ សឹម មែល ដែលចាត់ទៅនុំង ក្នុងឋានៈជាលេខា-- ប្រធានយោធា ជាអនុលេខាអនុសេនាធំមួយ ។ ដូច្នេះ ជាមួយបក្សជន គេត្រូវតែឲ្យខ្ញុំដឹង នេះជាករណីមួយ ។ សូមជម្រាបជូនទៀត ករណីមួយទៀត ដែលមាននៅក្នុងឯកសារម្សិលមិញ យើងបានតទល់គ្នាហើយ គឺឯកសារមួយដែលនិយាយអំពីគ្រួសាររបស់ ស៊ិន ដារ៉ា ហៅ សុខ ហើយនិងគ្រួសារបង ម៉ៃ លន់ ។ មេផ្តាំ មុននឹងចាត់ចែងលើពួកនេះ សូមយោបល់គាត់សិន សូមឲ្យគាត់សម្រេច ដូច្នេះករណីពិសេសបែបនេះ គេត្រូវរាយការណ៍ឲ្យខ្ញុំ ខ្ញុំសុំយោបល់មេ នេះជាករណីពិសេស ។ បង ម៉ៃ លន់ (សូមទោស) គ្រួសារបង ម៉ៃ លន់ ហើយនិងគ្រួសារមិត្តសុខ ឈ្មោះដើម ស៊ិន ដារ៉ា នេះមេផ្តាំអ៊ីចឹង ។ គាត់ជាកងសមាសភាពដែលយកទៅទុកតាមដាននៅនុំងៗ ដូច្នេះ ទាល់តែមានករណីពិសេសអ៊ីចឹង បានគេរាយការណ៍ឲ្យខ្ញុំ ។

**ស៖** សំណួរបន្ត លោកនិយាយថា ការអប់រំកែប្រែលើសមាសភាពនៅព្រៃស គឺលត់ដំឲ្យខំធ្វើពលកម្ម និងគោរពវិន័យគ្មានលក្ខខណ្ឌ ។ ដូច្នេះ ដើម្បីឲ្យសម្រេចបាននូវគោលដៅនេះ តើលោកមានផ្តល់វិធានការអ្វីខ្លះឲ្យបុគ្គលិកលោកនៅនោះដែរឬទេ?

[០៩:១៥:០០]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! និយាយឲ្យចំតែបញ្ហានេះ ខ្ញុំមិនបានផ្តល់មតិយោបល់ ឬក៏បើកវគ្គរៀនសូត្រអីពិសេសដល់បុគ្គលិកនៅទីនោះទេ ។ កិច្ចដំណើរនេះ វាហួរហែមានតាំងពីចាប់ក្រោយ១៧ មេសា បន្តិចមក ហើយដំណើរការធម្មតាតទៅ អប់រំជាពិសេស គឺអត់ តែអប់រំប្រចាំថ្ងៃ-- អប់រំប្រចាំឆ្នាំ តាមមាគ៌ាបក្សដែលខ្ញុំបានទៅរៀន គឺមានអប់រំ ។

**ស៖** បើគ្មានទេ តើលោកដឹងទេថា បុគ្គលិករបស់លោកនៅស-២៤ ជាពិសេស គឺហ៊ុយ ស្រែ ធ្វើដូចម្តេចទើបឱ្យសមាសភាពទាំងនោះគោរពវិន័យដោយគ្មានលក្ខខណ្ឌ និងខំធ្វើការ សូមលោកបញ្ជាក់មើល?

**ឆ៖** រឿងនេះការគោរពវិន័យដោយឥតលក្ខខណ្ឌ ហើយនិងការខំធ្វើការ វាជាគោលការណ៍យុទ្ធសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជា ដែលអង្គភាពណាក៏ដោយ សុទ្ធតែចង់ឱ្យបានសម្រេចទិសដៅនេះរបស់បក្សកំណត់ ។ នេះហើយដែលគេហៅថាសតិអារម្មណ៍អង្គការវិន័យដែលគេរៀននោះ ដែលគេរៀនម្តងៗ មួយឆ្នាំៗ វាមាននយោបាយ សតិអារម្មណ៍ និងចាត់តាំង ។ សតិអារម្មណ៍ជាគោលធំ ហ្នឹង ហើយសតិអារម្មណ៍អង្គការវិន័យ ពុះពារខំធ្វើការ គោរពវិន័យដោយឥតលក្ខខណ្ឌ ហ្នឹងវាស្ថិតនៅក្នុងគោលការណ៍នេះ ។ រាល់ឆ្នាំគេបង្រៀនបែបនេះ ពេលទិតៀនស្វ័យទិតៀន ក៏យើងទិតៀនគ្នាបែបនេះ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** អរគុណ ។ សំណួរបន្ត លោកបាននិយាយថា ព្រៃស ជាគុកឥតជញ្ជាំង គ្មានអ្នកណាម្នាក់ ប៉ានរត់ ប៉ានបះបោរ តើលោកដឹងទេថា វិធីសាស្ត្រអ្វីត្រូវអនុវត្តនៅទីនោះ ដើម្បីឱ្យសមាសភាពទាំងនោះភ័យខ្លាច មិនប៉ានរត់ មិនប៉ានបះបោរ សូមលោកបញ្ជាក់?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! វិធីសាស្ត្រដែលមិនឱ្យពួកនោះមិនប៉ានរត់ មិនប៉ានបះបោរ យើងធ្វើការជាប់ជាមួយនឹងគេ បុគ្គលិករបស់មន្ទីរស-២១ ធ្វើការជាប់ជាមួយនឹងគេ ។ ដូច្នេះ ដឹងចិត្ត ដឹងថ្លើម ដឹងអីរបស់គេ ថាអ្នកណាគេ មនុស្សណាបែបម៉េច មនុស្សណាស្តាប់យើង មនុស្សណាមិនស្តាប់យើង យើងយល់ ។ ទន្ទឹមគ្នានឹងទៅលួចស្តាប់យប់ទៀត កាន់តែច្បាស់ ។

ដូច្នេះ វិធីសាស្ត្រតាមដានជាបញ្ហាគន្លឹះមួយហើយ តាមដានហើយរាយការណ៍សុំយោបល់ខាងលើ គឺមិត្តហ៊ុយ ជាបញ្ហាទីពីរទៀត ជំហានទីពីរហ្នឹងទៀត ។ ដូច្នេះ វិធីសាស្ត្រវាមានពីរជំហានអ៊ីចឹង ទីមួយគឺបុគ្គលិកខ្លួនឯងនុ៎ង វាធ្វើការជាប់ជាមួយនឹងពួកនោះ ។ ទីពីរទៅលបស្តាប់យប់ ឮកាលណានិយាយមិនសង្ស័យ ឬឃើញភ្នែកអីមិនស្រួលបួល គឺគេចាប់អារម្មណ៍ហើយ គេតាមដាន ។ ដូច្នេះ ទីមួយ គឺការតាមដានយប់ ការតាមដានថ្ងៃ រាយការណ៍សុំយោបល់ សុំវិធានការណ៍ថ្មីពីមេ គឺមិត្តហ៊ុយ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** អរគុណ ។ ប្រសិនបើមានសមាសភាពណាម្នាក់រត់ តើមានការតាមចាប់ខ្លួនសាច់ញាតិរបស់គេទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ការតាមចាប់ខ្លួន មិនអាចធ្វើទៅបានដោយគ្មានឆ្លងតាមខ្សែរយៈចាត់តាំងច្បាស់លាស់ទេ ។ វាទាល់តែឆ្លងតាមខ្សែរយៈចាត់តាំង បាន១ទៅបាន នេះគឺសូមបញ្ចាក់ជូនប៉ុណ្ណេះ ។

**ស៖** បុគ្គលិករបស់លោកម្នាក់ដែលកាន់តេអូ ហើយរត់គេចខ្លួន តើមានរាយការណ៍ទៅថ្នាក់លើទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! បុគ្គលិកអ្នកកាន់តេអូ នៅព្រៃស ដែលរត់នេះទីមួយ ខ្ញុំបានរាយការណ៍ជូនមេ ពេលនោះពូ នួន គាត់នៅធ្វើមេខ្ញុំ រួចហើយយើងខ្ញុំចាប់អារម្មណ៍រាយ-ការណ៍ ជូនពូនួន អំពីបញ្ហាមិត្តហ៊ុយ ។ កាលណាយុទ្ធជនម្នាក់ដែលស្និទ្ធជាមួយនឹងមេ រត់ មានបាតុភាពអ៊ីចឹង បក្សចាប់អារម្មណ៍មេ នេះគឺ១វាឆ្លើយប្រវត្តិទៅអ៊ីចឹង ។ ខ្ញុំសូមលើកឧទាហរណ៍ជូនលោកព្រះរាជអាជ្ញា អ៊ីចឹងចុះ ខ្ញុំហើយនិងមិត្ត ប៉ុន ខ្ញុំស្និទ្ធណាស់ បក្សជ្រាប អ្នកណាក៏ឃើញ បើមិត្ត ប៉ុន រត់ ស្វ័យប្រវត្តិបក្សចាប់ខ្ញុំហើយ អត់និយាយច្រើនទេ ។ ខ្ញុំធានាប្រវត្តិរូប ប៉ុន ចំពោះមុខបក្ស ដូច្នេះ ហ៊ុយ ក៏គេធានាប្រវត្តិរូបអ្នកកាន់ តេអូ របស់គេចំពោះមុខបក្សដែរ ។ នេះអត់គិតទាន់ទៅដល់គ្រួសារឯនោះទេ គិតត្រឹមឯនេះសិន ។ មិត្តហ៊ុយ ជាបង្គោលធំលើអ្នកកាន់តេអូហ្នឹង ។ នេះសូមជម្រាបជូនលោកព្រះរាជអាជ្ញាប៉ុណ្ណេះ ។

**ស៖** តើមានវិធានការអ្វីតាមរកចាប់ខ្លួន ដែលអ្នកកាន់តេអូនោះដែរ ឬទេ?

**ឆ៖** វិធានការនេះវាស្រេចនៅខាងលើទេ ព្រោះយើងអត់មានសិទ្ធិទៅទាក់ទងជាមួយមូលដ្ឋាន គេដើម្បីតាមចាប់អ្នកនោះបានទេ ហើយមិនមានសិទ្ធិបញ្ចេញកម្លាំងទៅតាមចាប់ដែរ ។

[០៩:២១:១៨]

**ស៖** អរគុណ ។ សំណួរបន្ត នៅអំឡុងពេលសាកសួរពីអង្គហេតុម-១៣ ឃើញថាមានការប្រើវិធីសាស្ត្រសម្លាប់មនុស្ស សម្លាប់អ្នកទោសដើម្បីគំរាមកំហែងដល់អ្នកទោសដទៃទៀត តើលោកមានយកវិធីសាស្ត្រនេះ មកអនុវត្តនៅព្រៃស ឬ ស-២៤ ដែរឬទេ?

**ឆ៖** ជាផ្ទាល់ខ្លួនខ្ញុំ ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! កាលដែលឲ្យមិត្តម្នាក់ទៅបាញ់ជនរងគ្រោះម្នាក់នោះ មិត្តដែលខ្ញុំឲ្យបាញ់នោះ គឺមិត្តហ្នឹងឯងដែលបណ្ដោយឲ្យគេឆក់កាំភ្លើងបានកាលនៅក្បែរជើងភ្នំពីសនោះ ។ ហើយបាញ់ប៉ុន្មានថ្ងៃ គាត់តក់ស្លុតក្នុងចិត្តគាត់ គាត់ចេញទៅបាត់ទៅ ។ ឯចំណែកខ្ញុំក៏ខ្ញុំតក់ស្លុតដែរ ។ ដូច្នេះ ខ្ញុំអត់ប៊ានរំឭកព្រឹត្តិការណ៍នេះយកមកនិយាយទៀតទេ ។ ជាក់ស្ដែង

តាំងពីសម័យ ណាត កាន់កាប់មកខ្ញុំមិនដែលឮសួរបញ្ហានេះមកដល់ត្រចៀកខ្ញុំទេ មកដល់ខ្ញុំកាន់កាប់អាស-២៤ នេះថែមទៅទៀត ក៏ខ្ញុំមិនដែលបានណែនាំបញ្ហានេះឲ្យគេអនុវត្តន៍ដែរ អត់មានទេ ។

**ស៖** សំណួរបន្ត តើលោកជឿថា បុគ្គលិករបស់លោកនៅព្រៃស ពិសេស ហ៊ុយ អាចប្រើវិធីសាស្ត្រនេះដែរឬទេ?

**ឆ៖** ខ្ញុំមិនជឿថា គេអាចប្រើអាហ្នឹងទេ ។

**ស៖** អរគុណ ។ សំណួរបន្ត សមាសភាពដែលមានជំងឺ ពួកគេត្រូវអនុញ្ញាតឲ្យសម្រាកដែរឬទេ ឬមួយបង្ខំឲ្យធ្វើការទាំងឈឺ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! រឿងនេះខ្ញុំមិនជាក់ស្តែងនឹងភ្នែកទេ ឯចំណែកជនរងគ្រោះដែលមានមក ខ្ញុំរង់ចាំស្តាប់ទុក្ខវេទនារបស់គេ ខ្ញុំរង់ចាំទទួល ។ ខ្ញុំមិនជាក់ស្តែងនឹងភ្នែកទេ ។

**ស៖** លោកមានដឹងទេថា ពេលដែលសមាសភាពធ្វើការ បង្ខំឲ្យធ្វើការ ហើយធ្វើការមិនបានតាមផែនការត្រូវសន្តិសុខ ជាបុគ្គលិកកូនចៅរបស់លោកធ្វើទារុណកម្មទៅលើគេនៅពេលនោះ លោកមានដឹងទេ?

**ឆ៖** ខ្ញុំមិនដឹងនឹងត្រចៀកទេពីកាលនោះ ក៏ប៉ុន្តែដល់ឥឡូវនេះឮខ្ញុំទទួលបាន ឥឡូវនេះខ្ញុំឮ ខ្ញុំទទួលបានថាពិតជាមានបញ្ហានេះ ។

**ស៖** សំណួរបន្ត លោកបាននិយាយថា សមាសភាពដែលនៅព្រៃស បើប្រព្រឹត្តិឲ្យមានកំហុសនឹងបញ្ជូនទៅស-២១ ឬបញ្ជូនទៅជើងឯកផ្ទាល់តែម្តង តើកំហុសនោះគឺជាកំហុសអ្វីខ្លះ ទើបលោកចាត់ការតាមវិធីនេះ?

[០៩:២៤:៥០]

**ឆ៖** កំហុសធ្ងន់មានពីរបែប ។ ទីមួយ មានផែនការរកបះបោរ ។ ទីពីរ មានផែនការរករត់ នេះកំហុសធ្ងន់ ។ ឯចំណែក កំហុសក្នុងរឿងមិនខ្ជះខ្នែងការងារ ជាកំហុសទុកជាទីពីរទេ គេខំនិយាយ គេខំពន្យល់ គេខំរុញទៅ បើមិនបានទេ អាហ្នឹងគេរកវិធីរាយការណ៍មកសុំសម្រេចកម្មេច ។

**ស៖** លោកបញ្ជាក់កំហុសយ៉ាងម៉េចបញ្ជូនទៅស-២១? កំហុសយ៉ាងម៉េចបញ្ជូនទៅជើងឯកសម្លាប់ផ្ទាល់?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! បញ្ហានេះ ខ្ញុំសូមបញ្ជាក់បន្ថែមពីម្សិល ការបញ្ជូនទៅជើងឯកផ្ទាល់ ពេលណាវិភាគឃើញថា មនុស្សនោះមិនមានសារសំខាន់សម្រាប់យកចម្លើយ ។

ចម្លើយក៏មិនមានវែងឆ្ងាយអីដែរទេ នេះគឺបញ្ជូនទៅជើងឯកផ្ទាល់ មនុស្សណាដែលយើងខ្ញុំយល់ឃើញថាមានសារសំខាន់សម្រាប់យកចម្លើយ អាហ្នឹង គឺបញ្ជូនយកមកភ្នំពេញដើម្បីយកចម្លើយសម្រាប់រាយការណ៍តទៅទៀត ។

**ស៖** កំណត់លើគោលការណ៍អីបានដឹងថា ត្រូវបញ្ជូនទៅស-២១ និងទៅជើងឯកផ្ទាល់?

**ឆ៖** នេះកំណត់រួមផ្សំៗលើប្រវត្តិរូបរបស់បុគ្គលនុ៎ង ដែលមិត្តហ៊ុយ និងមិត្តហ៊ី គេក្តាប់បាន ។ រួមផ្សំនឹងសកម្មភាព រួមផ្សំនឹងអតីតភាពរបស់គេ អតីតភាពនៅឯណា ប៉ុន្តែ អតីតភាពវាផ្នែកមួយនៃប្រវត្តិហើយ ។ ដូច្នេះ រួមផ្សំនឹងប្រវត្តិរូប ហើយនិងអំពើជាក់ស្តែង ។ នេះគឺសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** សំណួរបន្ត តើក្មេងទាំង១៦០នាក់ បញ្ជូនទៅជើងឯកផ្ទាល់នោះ មុននឹងបញ្ជូនទៅជើងឯកនោះ គេរស់នៅនឹង ស-២៤ រយៈពេលប៉ុន្មាន?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ។ ខ្ញុំមិនជាក់ស្តែងទេៗ ខ្ញុំគ្រាន់តែអាចសន្និដ្ឋានបានថា ក្មេងទាំងបញ្ជូនទៅជើងឯកទាំង១៦០នាក់នេះ គឺជាក្មេងដែលគេទុកយូរម្នាក់ម្តង ពីរបីបួននាក់បីបួននាក់ថែមទៅទៀតៗ គេទុកយូរ ហើយគេប្រើ ដូចជាខ្ញុំបានជម្រាបម្សិលមិញអ៊ីចឹង ក្មេងធំៗគួរសមយប់ឡើងដើរចាប់កណ្តុរស៊ីស្រូវ អាហ្នឹងពេលខែវស្សា ពេលស្រូវទុំ ។ នេះប៉ុណ្ណឹងឯង។ ដូច្នេះ ខ្ញុំមិនជាក់ស្តែងថា នៅប៉ុន្មានខែៗទេ ហើយតាមពិតចំនួនខែដែលរស់នៅយើងខ្ញុំប្រើគេនោះ វាអត់ស្មើគ្នាទេ អ្នកខ្លះយូរទៅ អ្នកខ្លះឆាប់ទៅ ។ នេះសូមបញ្ជាក់ជូនអ៊ីចឹង ។

**ស៖** តើពិតទេថា ដោយសារពួកគេជាក្មេង ដែលមិនមានកម្លាំងគ្រប់គ្រាន់ក្នុងការធ្វើពលកម្ម ហើយដោយសារតែ ស-២១ មិនចង់ចំណាយអាហារទៅលើពួកគេ ទើបយកពួកគេទៅសម្លាប់ ។ តើមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! នេះជាហេតុផលទីពីរទេៗ ។ ហេតុផលទីមួយ គឺបក្សកុម្មុយនីស្តកម្ពុជា ភ័យខ្លាចក្មេងសងសឹក កុមារកំព្រានោះសងសឹក នេះជាហេតុផលធំ ហេតុផលគន្លឹះ រកស្នើមកទប់ទល់អាហេតុផលគន្លឹះនេះអត់បានទេ ។

[០៩:២៩:០៩]

**ស៖** អរគុណ ។ សំណួរបន្ត តើប្រើមធ្យោបាយអ្វីដើម្បីយក្មេងទាំងនោះពីស-២៤ ទៅជើងឯក?

**ឆ៖** នេះជាបញ្ហាបច្ចេកទេស ខ្ញុំអត់បានដឹង ហើយអត់បានឃើញនឹងភ្នែកទេ ។ ខ្ញុំដឹងជាគោលការណ៍ គឺអត់ទុកក្មេងទេ ខ្លាចសងសឹក ត្រូវតែកម្ទេចជូនបក្ស។ ដូច្នេះ ជាគោល-- ជាបញ្ហាបច្ចេកទេស

ខ្ញុំអត់បានទៅឃើញនឹងភ្នែក ហើយខ្ញុំអត់បានគិតគូរតាមដេញដោលសួរគេទេ ។

[០៩:៣០:០០]

**ស៖** តាមធម្មតាអ្នកទោសដែលបញ្ជូនចេញត្រូវដឹកតាមរថយន្ត ហើយដាក់ខ្នោះ តើលោកអាចដឹងទេ តើក្មេងៗទាំងនោះ ពេលគេដាក់លើរថយន្ត គេមានដាក់ខ្នោះទេ?

**ឆ៖** ខ្ញុំមិនបានឃើញ ហើយក៏មិនប៉ាន់ប៉ាន់ប្រមាណដែរទេ នេះជម្រាបដោយត្រង់ ។

**ស៖** លោកថា ការសម្រេចសមាសភាពនៅស-២៤ គឺសម្រេចត្រឹមកម្រិតគណៈកម្មការ ស-២១ លោកមិនមានការស្នើសុំទៅលើទៅថ្នាក់លើ ដើម្បីសម្រេចទេ ចុះមានធ្វើរបាយការណ៍ពីការសម្លាប់ពីការបញ្ជូនទៅថ្នាក់លើដែរឬទេ?

**ឆ៖** ខ្ញុំនៅចាំបានថា ការរាយការណ៍មាន ក៏ប៉ុន្តែជាការមាត់ទទេ គ្មានឯកសារនៅសល់ទេ សូម្បីតែនៅមន្ទីរ៨៧០ ដែលខ្ញុំរាយការណ៍ឯកសារទៅ ក៏មិនមាននិយាយពីរឿងនុ៎ងដែរ ។ ជាមាត់ទទេមាន ។

**ស៖** អ៊ីចឹងលោកអាចព្រមព្រៀងគ្នាទេថា លោកជាអ្នកសម្រេចលើជោគវាសនានៃសមាសភាពទាំងនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! និយាយឲ្យចំទៅ ខ្ញុំក៏ដូចខាងលើដែរ ទទួលដឹងឮពីគេត្រឹមតែតួលេខប៉ុននុ៎ង ឯចំណែកការសម្រេចនៅលើគេ ពីក្រោមដែលខ្ញុំប្រគល់ឲ្យ គេសម្រេចទៅហើយតាំងពីដើមមក គេប្រកាន់កាប់កិច្ចការហ្នឹងតាំងពីដើមមក រក្សាទុកសិទ្ធិរបស់គេឲ្យគេប៉ុណ្ណឹង ។ ដូច្នេះខ្ញុំដឹងតួលេខ នេះជម្រាបដោយត្រង់ ។ ហើយរាយការណ៍ទៅលើក៏តួលេខដែរ ។

**ស៖** អរគុណលោកប្រធាន ។ ខ្ញុំអស់សំណួរ ហើយសូមប្រគល់វេទិកានេះទៅសហការីខ្ញុំសួរបន្ត ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយលោក វីលៀម ស្មីត៖**

សួស្ដីលោកប្រធាន សួស្ដីអស់លោក លោកស្រី សួស្ដីលោក កាំង ហ្គេកអ៊ាវ ! ខ្ញុំនឹងបន្តនៅចំណុចក្រោយដែលលោកបាននិយាយ ។

**ស៖** លោកនិយាយថា លោកមិនបានសម្រេចទៅលើវាសនារបស់សមាសភាពអស់ទាំងនោះទេ

និយាយអំពីវាសនារបស់សមាសភាពនោះ គឺសមាសភាព គឺអ្នកដែលជាប់ឃុំឃាំងនៅព្រៃស ។ ដូច្នេះ លោកមិនមែនជាអ្នកសម្រេច ថាតើពួកគេត្រូវសម្លាប់ ឬក៏រស់ទេ? តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ជាគោលការណ៍ គឺខ្ញុំទទួលខុសត្រូវលើសេចក្តីសម្រេចនេះ ទោះបីខ្ញុំមិនសម្រេចដោយផ្ទាល់ក៏ដោយ ក៏ខ្ញុំនៅតែទទួលខុសត្រូវលើសម្រេចនេះ ក៏ប៉ុន្តែជាក់ស្តែងក្នុងការធ្វើ គឺគេសម្រេច ។ ត្រូវគេធានាចំពោះមុខខ្ញុំ ទាំងពីរនាក់ធានាចំពោះមុខខ្ញុំ ក៏ដូចជាចំពោះមុខបក្សដែរ ។ ធ្វើម៉េចកុំឲ្យពួកសមាសភាពនេះ បះបោរបាន ធ្វើម៉េចកុំឲ្យពួកសមាសភាពនេះរត់រួច ។ នេះពីរនាក់នេះ ត្រូវធានាចំពោះមុខខ្ញុំ ក៏ដូចជាចំពោះមុខបក្សខាងលើកអ៊ីចឹង ។ នេះសូមជម្រាបលោកព្រះរាជអាជ្ញាប៉ុណ្ណេះ ។

**ស៖** លោក កាំង ហ្កេកអ៊ាវ អ្វីដែលខ្ញុំនឹងធ្វើនៅព្រឹកមិញនេះ គឺខ្ញុំនឹងលើកពីចំណុចដែលលោកនិយាយផ្ទុយគ្នានៅចំពោះមុខ សហចៅក្រមស៊ើបអង្កេត និងសក្ខីកម្មដែលលោកបានផ្តល់កាលពីម្សិលមិញ ក៏ប៉ុន្តែនឹងជាការប្រសើរជាង បើសិនជាយើងនិយាយអំពីចំណុចនោះឲ្យចំតែម្តង ។ ទាក់ទងទៅនឹងអ្នកដែលត្រូវបានឃុំខ្លួននៅស-២៤ ឬក៏ព្រៃស ហើយដើម្បីដឹកពួកគេ ឬក៏នាំពួកគេមកស-២១ នៅភ្នំពេញវិញនោះ តើលោកនិយាយថា នោះគឺជាសេចក្តីសម្រេចចិត្តរបស់លោក ឬក៏ជាសេចក្តីសម្រេចចិត្តរបស់អ្នកដែលនៅក្រោមបង្គាប់របស់លោកក្នុងការនាំអ្នកទាំងនោះពីព្រៃស មកស-២១? តើនោះគឺជាសេចក្តីសម្រេចចិត្តរបស់លោក ឬក៏ជាសេចក្តីសម្រេចចិត្តរបស់អ្នកនៅក្រោមរបស់លោក គឺហ៊ុយហើយនិង ហ៊ី ឬក៏ ហ៊ុយ ស្រែ នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! បើតាមខ្ញុំចាំនៅចំពោះចៅក្រមស៊ើបអង្កេតក៏ដោយ ក៏ខ្ញុំនិយាយថា ជាគោលការណ៍ គឺត្រូវគេទទួលខុសត្រូវចំពោះមុខខ្ញុំ ក៏ដូចជាចំពោះមុខបក្ស កុំឲ្យពួកនោះរត់រួច កុំឲ្យពួកនេះបះបោរបាន ។ រឿងល្អិតជាក់ស្តែងមួយៗ គេសម្រេចចុះ លើកលែងតែករណីក្រុមគ្រួសារមិត្តសុខ ហើយនិងក្រុមគ្រួសារបង ម៉ៃ លន់ ។ នេះខ្ញុំបានជម្រាបប៉ុណ្ណេះ ហើយលើកលែងពីពួកសាមសិបនាក់ ដែលមេខ្ញុំឲ្យយកមកអប់រំបណ្តោះអាសន្នមួយខែ ហើយបញ្ជូនចេញទៅវិញ ។ ដូច្នេះខ្ញុំនៅចាំ ថាខ្ញុំរក្សា ព្រោះរឿងហ្នឹងវាជារឿងពិត ។ ដូច្នេះ ខ្ញុំរាយការណ៍ជូនព្រះរាជអាជ្ញា នៃជូនលោកចៅក្រមស៊ើបអង្កេតប៉ុនណា ខ្ញុំនៅចាំប៉ុនន្នុង ខ្ញុំនៅជឿថា ខ្ញុំមិនឃ្លាតឆ្ងាយពីនុងទេ ។

**ស៖** សូមអរគុណ ។ លោក កាំង ហ្កេកអ៊ាវ យើងខ្ញុំយល់អំពីភាពលំបាកក្នុងការផ្តល់សក្ខីកម្មជាលម្អិតនៅចំពោះមុខចៅសហចៅក្រមស៊ើបអង្កេត និងនៅចំពោះមុខអង្គសវនាការនេះ ដោយលោក

ត្រូវបានសួរសំណួរជាច្រើនពីភាគីផ្សេងៗគ្នានោះ ។ ក៏ប៉ុន្តែ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ទាក់ទងនឹងអ្នកអស់ទាំងនុ៎ងដែលត្រូវបានត្រឡប់មកពីស-២១វិញ គឺមកពីព្រៃស លោកត្រូវបានប្រាប់ថា សេចក្ដីសម្រេចចិត្តនោះ ត្រូវបានធ្វើហើយ គឺបន្ទាប់ពីអ្នកអស់ទាំងនុ៎ង ត្រូវបានគេបញ្ជូនមកស-២១ រួចមកហើយ ។ អ៊ីចឹង គឺលោកមិនចូលរួមពាក់ព័ន្ធនៅក្នុងការសម្រេចចិត្តនោះទេ មានន័យថា ការសម្រេចចិត្តហ្នឹង គឺលោកបានប្រគល់តួនាទីហ្នឹងឲ្យទៅហ៊ិ និងហ៊ុយ ស្រែ រួចទៅហើយ ។ ហើយក្រោយមក ទៀតទេទើបលោកបានដឹងថា អ្នកជាប់ឃុំអស់ទាំងហ្នឹង ត្រូវបានគេដឹកត្រឡប់មកភ្នំពេញវិញ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំពិបាកជម្រាបណាស់បញ្ហានេះ ប្រសិនបើមានឯកសារថា ខ្ញុំជម្រាបលោកថៅក្រមស៊ើបអង្កេតយ៉ាងម៉េច ហើយភស្ដុតាងមកថ្មីទៀត វាយ៉ាងម៉េច ខ្ញុំនឹងជម្រាបស្រួលជាងនេះ ។ ហើយខ្ញុំសូមជម្រាបលោកព្រះរាជអាជ្ញាថា ខ្ញុំអត់មានបំណងកិច្ចកែអំពីឧក្រិដ្ឋកម្មរបស់ខ្ញុំទៅលើមនុស្សទេ ។ ខ្ញុំទទួល ។ ក៏ប៉ុន្តែកាលដែលយើងខ្ញុំឆ្លើយចំពោះមុខលោកថៅក្រមស៊ើបអង្កេត ឯកសារមកដល់ខ្ញុំតិច ឥឡូវឯកសារមកថែមទៀត ។ ដូច្នេះ គំនិតដែលនឹកឃើញតែរឿងចាស់ វាប្លែកគ្នា ដូច្នេះវាប្លែកតែប៉ុណ្ណឹងឯងទេ ។ សូមជម្រាបលោកព្រះរាជអាជ្ញាប៉ុណ្ណេះ ។

**ស៖** លោក កាំង ហ្កេកអ៊ាវ ខ្ញុំគិតថា គ្រប់គ្នាមានការពេញចិត្តចំពោះការទទួលខុសត្រូវរបស់លោកចំពោះឧក្រិដ្ឋកម្មអស់ទាំងនុ៎ង ដែលជាគោលការណ៍ទូទៅ ។ ប្រហែលជាលោកមិនបានគិតអំពីអ្វីដែលលោកបាននិយាយនៅចំពោះមុខសហថៅក្រមស៊ើបអង្កេត ឬក៏អ្វីដែលលោកបាននិយាយកាលពីម្សិលមិញ ក៏ប៉ុន្តែតើនៅពេលនេះ លោកអាចប្រាប់យើងបានទេ ពីការចងចាំរបស់លោកថា នៅពេលដែលលោកនៅ ស-២១ នោះ រឿងហេតុដែលបានកើតឡើងនោះ គឺលោកបានដឹងនៅពេលក្រោយហើយដែលថាពួកគេហ្នឹងត្រូវបានចាប់ខ្លួន ហើយក្រោយមកត្រូវបានគេដឹកយកមកស-២១វិញនៅភ្នំពេញ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ត្រឹមត្រូវ ។

**ស៖** ហើយដូចគ្នានេះដែរ តើជាការត្រឹមត្រូវទេ ដែលអ្នកអស់ទាំងនុ៎ងដែលត្រូវបានគេបញ្ជូនផ្ទាល់ពីព្រៃសទៅជើងឯកនោះ គឺមានន័យថា សេចក្ដីសម្រេចចិត្តក្នុងការបញ្ជូននោះ ត្រូវបានធ្វើឡើងដោយ ហ៊ិ ហើយនិង ហ៊ុយ ស្រែ ។ ហើយលោកគឺបានដឹងអំពីសម្រេចចិត្ត អំពីការសម្លាប់នោះនៅពេលក្រោយទេ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍ គឺត្រឹមត្រូវជាមូលដ្ឋាន ។ ខ្ញុំជម្រាបថា ត្រឹមត្រូវជាមូលដ្ឋាន ។

**ស៖** ខ្ញុំចង់ធ្វើការបញ្ជាក់ឡើងវិញ ពីអ្វីដែលបាននិយាយកាលពីម្សិលមិញនោះ ។ ដូច្នេះ ក៏ជាការត្រឹមត្រូវដែរឬទេ នៅពេលដែលខ្ញុំនិយាយថា លោកជឿជាក់ទុកចិត្តទៅលើ ហ៊ុយ ស្រែ ហើយនិង ហ៊ី ដែលជាសមាជិកគណៈ ស-២១ នោះ? គឺថាលោកជឿទុកចិត្តគេមែនទែន តើមែនដែរឬទេ?

[០៩:៤០:២៩]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ក្នុងការធ្វើការងារ ខ្ញុំជឿទុកចិត្តគេ នេះនិយាយមួយម៉ាត់ឲ្យខ្លី គឺយើងអាចនិយាយអ៊ីចឹង ។ ប៉ុន្តែ បើសិនអនុញ្ញាតឲ្យខ្ញុំបញ្ជាក់ ខ្ញុំសូមបញ្ជាក់ថា គេមិនដែលបានធ្វើឲ្យយើងទាំងអស់គ្នាមានគ្រោះថ្នាក់ ដោយបណ្តោយឲ្យមនុស្សរបះបោរបាន១ ។ នេះគឺជឿទុកចិត្តអ៊ីចឹង ហើយគេមិនបណ្តោយឲ្យមនុស្សរត់រួច ។ នេះគឺខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** ដូច្នេះក្រៅពីអ្នកកាន់វិទ្យុ កាន់ទូរស័ព្ទ កាន់វិទ្យុ ហើយក្រៅពីបញ្ហានេះ នៅក្រោយមកនៅក្នុងសម័យខ្មែរក្រហម លោកមានភាពអំនួតចំពោះហ៊ុយ ស្រែ និងហ៊ី ។ ចំពោះការអនុវត្តមាគ៌ាបក្ស ដូចជាបញ្ហាវិន័យក្នុងលក្ខណៈមួយហ្មត់ចត់ និងរឹងប៉ឹង តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំជឿ ជឿគេជាមូលដ្ឋាន ។

**ស៖** ដើម្បីបញ្ចប់ទៅលើចំណុចនេះ លោកមានការគ្រប់គ្រងពិតប្រាកដ និងដាក់ស្តែទៅលើហ៊ុយ ស្រែ និង ហ៊ី នូវអ្វីដែលពួកគេបានធ្វើ ។ នៅពេលដែលខ្ញុំនិយាយដូច្នេះ បានន័យថា នៅពេលដែលលោកចង់បញ្ឈប់ ហ៊ី មិនឲ្យធ្វើអ្វីមួយ ឬក៏បញ្ឈប់ ហ៊ុយ ស្រែ មិនឲ្យធ្វើអ្វីមួយនោះ លោកអាចមានអំណាចគ្រប់គ្រងនោះដោយងាយ ដោយសារតែអំណាច និងតួនាទីរបស់លោក តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! អំណាចរបស់ខ្ញុំពេញដៃ ចង់ដឹងរឿងអីដឹងបាន ហៅមករាយការណ៍ឲ្យឥឡូវហ្នឹង ចង់បញ្ឈប់រឿងអីបញ្ឈប់បាន ចង់តម្រង់រឿងអីតម្រង់បាន ។ នេះអំណាចរបស់ខ្ញុំ គឺពិតមាន មានពិត ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** ហើយខ្ញុំគិតថា យើងទាំងអស់គ្នាអាចយល់ ហេតុអ្វីបានជាលោកបានផ្តល់អំណាចរបស់លោកទៅឲ្យ ហ៊ី និងហ៊ុយ ស្រែ ។ ការផ្តល់នោះ ផ្តល់អំណាចនោះ គឺដោយសារតែមានការងារច្រើនណាស់ត្រូវធ្វើនៅស-២១ មានការងារច្រើនក្នុងការចាត់ចែង និងការអប់រំ ហើយមានការងារច្រើនក្នុងការធ្វើចំណារ ។ ហើយព្រៃស ក៏ជាអង្គភាពផលិតផ្នែកស្រូវ និងកសិកម្មមួយដ៏ធំ ហើយដោយសារតែបញ្ហានេះ គ្មានវិធីណាមួយនៅក្នុងពិភពលោកដែលថា លោកអាចចូលរួមការងារគ្រប់ទាំងអស់ដែលត្រូវ

ធ្វើនោះទេ ។ ដូច្នេះ សេចក្តីសម្រេចលើការសម្លាប់ លើការធ្វើទារុណកម្ម សេចក្តីសម្រេចលើការរក្សាស្ថានភាពទាំងអស់នោះ គឺដូច្នេះហើយទើបលោកផ្តល់អំណាចទៅដល់ពួកគេ ដោយសារតែលោកមិនអាចធ្វើការគ្រប់គ្រងការងារទាំងអស់នោះ ។ តើនិយាយដូច្នេះត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ត្រឹមត្រូវជាមូលដ្ឋានហើយ ហើយខ្ញុំគ្រាន់តែបញ្ជាក់បន្ថែមមួយម៉ាត់ថា ការងារនេះគេធ្លាប់ធ្វើរួចមកហើយ ទុកឲ្យគេធ្វើទៅចុះ ។

**ស៖** ខ្ញុំគិតថា ខ្ញុំក៏យល់ផងដែរថា ចំពោះអ្នកទោសសំខាន់ៗ អ្នកទោសដែលប្រហែលជាមកពីព្រៃសនោះ ហេតុអ្វីបានជាលោកត្រូវទាក់ទងថ្នាក់លើរបស់លោកចំពោះពួកគេ ដោយសារតែពួកគេទាំងអស់នោះគឺមានការគំរាមកំហែងទៅដល់បក្សកុម្មុយនីស្តកម្ពុជាហើយនោះ ។ ដោយសារបញ្ហានេះហើយទើបលោកធ្វើការទាក់ទងទៅដល់ថ្នាក់លើរបស់លោក ចំពោះអ្នកដែលនាំខ្លួនមកពីស-២៤ ទៅស-២១ តើវាត្រឹមត្រូវដែរឬទេ? នេះជាចំណុចសំខាន់ ។

[០៩:៤៥:១៣]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ការយល់ឃើញរបស់លោកត្រឹមត្រូវហើយ ។ ចំពោះមនុស្សដែលទាក់ទងនឹងគ្រួសារបង ម៉ែ លន់ ហើយនិងគ្រួសារមិត្ត សុក ឈ្មោះដើមហៅ ស៊ិន ដារ៉ា ។

**ស៖** យើងត្រឡប់ទៅដល់របាយការណ៍ដែលលោកទទួលបាន ហ៊ុយស្រែ និងហ៊ី ដែលរបាយ-ការណ៍នោះស្តីអំពីការចាប់ខ្លួនបុគ្គលិកពីព្រៃសបញ្ជូនមកភ្នំពេញ ហើយនិងរបាយការណ៍ស្តីអំពីការសម្លាប់អ្នកជាប់ឃុំនៅជើងឯកដែលបញ្ជូនពីព្រៃស ។ វាត្រឹមត្រូវនឹងការលើកឡើងដែរឬទេថា ការងារទាំងអស់នោះវាលេចឡើងក្នុងអំឡុងពេលរយៈពេលបីឆ្នាំ ។ បានន័យថា មនុស្សទាំងឡាយមិនត្រូវបានគេនាំមកព្រៃស-- ពីព្រៃស មកភ្នំពេញនៅ ស-២១ គឺជាក្រុមទីមួយ ។ គឺការងារនេះវាកើតឡើងក្នុងអំឡុងជាច្រើនខែ ច្រើនអាទិត្យក្នុងមួយឆ្នាំ ដូច្នេះបានន័យថា បុគ្គលត្រូវបានបញ្ជូនពីព្រៃស ទៅជើងឯកគឺវាកើតឡើងដូច្នេះ ។ ដូច្នេះហើយវាជាការព្រួយបារម្ភទៅដល់ ហ៊ី និង ហ៊ុយស្រែ ។ គឺត្រឹមត្រូវដែរឬទេដែរថារបាយការណ៍វាបញ្ជូនមកលោកទាក់ទងទៅនឹងបាតុភាពទាំងអស់នោះក្នុងរយៈពេលបីឆ្នាំនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំជម្រាបដោយត្រង់ចុះដោយសារបញ្ហាខ្ញុំស្តាប់អង់គ្លេសក៏មិនបាន ហើយអ្នកបកប្រែក៏មានកម្រិត ដូច្នេះ ខ្ញុំសូមសាកល្បងឆ្លើយតាមការយល់ដឹងរបស់ខ្ញុំ ។ ខុសត្រូវយ៉ាងម៉េចសូមលោកព្រះរាជអាជ្ញាសួរបញ្ជាក់មកថែមទៀតចុះ ។

ទីមួយ ខ្ញុំសូមឆ្លើយថា គ្នាអ្នកប្រតិបត្តិទាំងពីរនាក់ ហ៊ី និងហ៊ុយ ជាពិសេស ហ៊ុយ ដែលចុះផ្ទាល់

នឹងការងារហ្នឹងជាងគេ ព្រួយបារម្ភណាស់ដែលខ្លួនឯងត្រូវធានាខុសត្រូវចំពោះមុខបក្សក្នុងការមិនឲ្យបុគ្គលទាំងនោះបះបោរបាន ក្នុងការធានាថាមិនឲ្យបុគ្គលទាំងនោះរត់បាន ហើយនិងក្នុងការធានាថាធ្វើម៉េចឲ្យការបង្កបង្កើនផលវាបានជឿនលឿន ហើយនិងឲ្យគេចេះគោរពវិន័យដោយឥតលក្ខខណ្ឌ ជាការពិបាករបស់គេ ។ ងាកមកខាងលើវរល់មិនបានជួយមតិគេ ដូច្នេះ ជាការលំបាករបស់គេដោយពិត។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។ ខុសត្រូវនឹងសំណួររបស់ព្រះរាជអាជ្ញាយ៉ាងម៉េចសូមអធ្យាស្រ័យហើយសូមសួរមកទៀតចុះ ។

[០៩:៤៨:៣០]

**ស៖** សូមអភ័យទោសដោយសារតែសំណួររបស់ខ្ញុំវាវែងពេក ប្រហែលខ្ញុំអាចសួរដោយខ្លីៗ ។ របាយការណ៍ស្តីពីការសម្លាប់នៅជើងឯកនិងរបាយការណ៍ស្តីពីការចាប់ខ្លួននៅព្រៃស បញ្ជូនមកស-២១ នៅភ្នំពេញ ។ របាយការណ៍ទាំងអស់នោះ គឺបានបញ្ជូនមកលោកតាមរយៈហ៊ី ហើយប្រហែលតាមហ៊ុយស្រែ ផងដែរ ។ នៅក្នុងរយៈពេលមួយទៀងទាត់ ក្នុងរយៈពេលបីឆ្នាំនៃការប្រតិបត្តិការស-២១ ។

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ហ៊ុយ ស្រែ ជាអ្នករាយការណ៍មកខាងលើ មកគណៈ ក្នុងឋានៈគាត់ជាសមាជិកម្នាក់របស់គណៈកម្មាធិការ ស-២១ គាត់រាយការណ៍មកគណៈ ។ ដូច្នេះ គាត់រាយការណ៍មកជាគោលការណ៍ គឺទៀងទាត់របស់គាត់ ។ ខ្ញុំមិនចាំច្បាស់ថា តើប្រចាំខែ ឬក៏ប្រចាំអាទិត្យទេ ខ្ញុំចាប់អារម្មណ៍រំឭកឡើងវិញថា អាចប្រចាំខែច្រើនជាង ។ នេះជាទូទៅ ក៏ប៉ុន្តែក្នុងករណីពិសេសក៏គាត់មានរាយការណ៍ជាក់ស្តែងបញ្ជោខ្លះមកដែរ បើមិនបានជាលាយលក្ខណ៍អក្សរទេក៏ជាមាត់ទទេមក ។ ហ្នឹងខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** សូមអរគុណ ។ ដូច្នេះ វាត្រឹមត្រូវក្នុងការលើកឡើងដែរឬទេថា លោកបានផ្តល់ទំនួលខុសត្រូវមួយចំនួនទៅដល់ហ៊ី និង ហ៊ុយស្រែ ជាពិសេស គឺការទទួលខុសត្រូវលើព្រៃស ទាក់ទងទៅនឹងសមាសភាព១៣០០នាក់ ដែលត្រូវបានគេឃុំនៅទីនោះ នៅក្នុងឆ្នាំ១៩៧៧ និងលើបុគ្គលិកស-២១ និងគ្រួសាររបស់ពួកគេដែលត្រូវបានគេឃុំនៅស-២៤ ។ លោកផ្តល់ការទទួលខុសត្រូវក្នុងលក្ខណៈមួយធំទៅដល់បុគ្គលទាំងពីររូបនេះ ដោយសារតែអ្នកទាំងពីរនោះ គឺជាអ្នកដែលធ្វើសេចក្តីសម្រេច ហើយគាត់ទាំងពីរនោះធ្វើការសម្រេចទៅលើបុគ្គលក្នុងចំណោមអ្នកទាំងអស់នោះនៅព្រៃស ថាតើត្រូវស្លាប់ ឬក៏រស់ ។ ដូច្នេះ គឺពួកគេមានទំនួលខុសត្រូវធំណាស់ ដែលលោកជាអ្នកផ្តល់ទៅឲ្យពួកគេ ។ តើលោកយល់ស្របដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ដំបូងខ្ញុំសូមញែកបញ្ហានេះជាពីរ ។ ទីមួយ បុគ្គលិករបស់ ស-២១ នៅព្រៃស វាមានឋានៈខាងសិទ្ធិអំណាចខ្ពស់ជាងពួកសមាសភាពឆ្ងាយណាស់ ។ ដើម្បីចាប់ចងបុគ្គលិករបស់ស-២១ ដែលធ្វើការនៅព្រៃស ត្រូវឆ្លងមកដល់ខ្ញុំ ហើយខ្ញុំសុំអនុញ្ញាតពីខាងលើសិន ។ នេះជាបញ្ហាមួយ ។ បញ្ហាពីរ គឺពួកសមាសភាពទាំងបីក្រុម ទាំងបីប្រភេទដែលខ្ញុំបានរាយ-ការណ៍ជូនអង្គសវនាការម្សិលមិញរួចហើយ ជាការប្រគល់បន្ទុកមួយធ្ងន់ពិតមែនទៅឲ្យគេ ខ្ញុំអត់ប្រកែកទេ នេះបន្ទុកនេះគឺប្រគល់ទៅឲ្យគេ ។ ម៉េចក៏បានជាប្រគល់ផ្ដាច់ទៅឲ្យគេ? មាគ៌ាបក្សកំណត់មកអ៊ីចឹងមាគ៌ាចាត់តាំង ។ មនុស្សដែលជាពាក់កណ្ដាលអ្នកទោសហើយ ថ្នាក់ខាងក្រោមអាចសម្រេចបាន មិនឈានទៅដល់អចិន្ត្រៃយ៍ទេ សម្រេច ។ ដូច្នេះ បន្ទុករបស់គេនៅលើមនុស្សជាពាក់កណ្ដាលអ្នកទោសនេះគឺពិតជាបន្ទុកធ្ងន់មែនៗ ។ នេះសូមជម្រាបលោកព្រះរាជអាជ្ញាប៉ុណ្ណោះដោយគោរព ។

[០៩:៥២:៣៨]

**ស៖** សូមអរគុណ ហើយប្រហែលជាខ្ញុំចង់សួរសំណួរខ្លីៗមួយចំនួនទៀតទាក់ទងទៅនឹងរបាយការណ៍-- របបរាយការណ៍ ។ ខ្ញុំមិនចង់និយាយពិស្ដារទៅលើចំណុចនេះទេ ប៉ុន្តែ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតលោកបានលើកឡើងថា របាយការណ៍នោះ គឺបានបញ្ជូនមកពីព្រៃស ជាប្រចាំថ្ងៃមកស-២១ ហើយលោកបានលើកនិយាយអំពីរបាយការណ៍ស្ដីអំពីស្រូវ និងរបាយការណ៍លើបុគ្គលិកទាក់ទងទៅនឹងបុគ្គលិកគាត់ឈើ ហើយមានអ្នកណាធ្វើការប៉ុន្មាននាក់? របាយការណ៍ទាំងអស់ នោះបានបញ្ជូនមកស-២១ ជាប្រចាំថ្ងៃ ។ ហើយលោកក៏បានលើកឡើងអំពីរបាយការណ៍ទាក់ទងទៅនឹងបាតុភាពផ្សេងៗដែលកើតឡើងនៅព្រៃស ដែលវាទាមទារឲ្យមានការពាក់ព័ន្ធពីលោកទៅលើរបាយការណ៍ទាំងអស់នោះ ។ ហើយលោកក៏បានលើកឡើងនៅថ្ងៃនេះផងដែរថា លោកទទួលបានរបាយការណ៍ស្ដីអំពីការស្លាប់នៃបុគ្គលដែលត្រូវបានបញ្ជូនទៅជើងឯក ហើយនិងរបាយការណ៍ស្ដីអំពីការចាប់បុគ្គលពីព្រៃសបញ្ជូនមកស-២១ នៅភ្នំពេញ ។ ដូច្នេះ វាមានការលំបាកក្នុងការនិយាយអំពីរបាយការណ៍ មួយប្រភេទដែលវាទាក់ទងទៅនឹងរបាយការណ៍ស្ដីអំពីចំណុចផ្សេងៗ ។ សំណួរ នៅពេលដែលលោកនិយាយអំពីរបាយការណ៍ដែលលោកទទួលជាប្រចាំថ្ងៃនិងប្រចាំសប្ដាហ៍ ហើយអម្បាញ់មិញនេះលោកបានលើកឡើងថា លោកបានទទួលរបាយការណ៍ជាប្រចាំខែផងដែរ ។ តើវាត្រឹមត្រូវក្នុងការលើកឡើងដែរឬទេថាយោងទៅលើរបាយការណ៍ចម្លើយទាំងឡាយដែលលោកបានលើកឡើងនោះ គឺលោកទទួលបានព័ត៌មាននិងគេប្រាប់លោកអំពីគ្រប់កិច្ចការទាំងអស់ដែលកើតឡើងនៅព្រៃស តាមរយៈការប្រជុំជាប្រចាំថ្ងៃរបស់

លោកជាមួយ ហ៊ា គឺការប្រជុំពីរទៅបីដងក្នុងមួយថ្ងៃ ហើយនិងដោយសារតែលោកធ្វើការទំនាក់ទំនងជាមួយ ហ៊ុយស្រែ តើវាត្រឹមត្រូវក្នុងការលើកឡើងដែរឬទេថា គេប្រាប់ព័ត៌មានលោកច្រើនណាស់អំពីអ្វីដែលកើតឡើងនៅស-២៤? ប៉ុន្តែ វាពិបាកណាស់ដែរថា សាមសិបឆ្នាំក្រោយមកលោកចងចាំទៅលើចំណុចនេះទាំងអស់ ជាពិសេសថា តើលោកទទួលរបាយការណ៍នោះក្នុងលក្ខណៈញឹកញាប់ប៉ុនណា? ហើយទទួលបានច្រើនប៉ុនណា? ហើយវាជាសំណួរវែងដដែល ប៉ុន្តែយ៉ាងហោចណាស់ គឺលោកអាចព្យាយាមឆ្លើយបើសិនជាលោកឆ្លើយមិនបាន គឺខ្ញុំអាចធ្វើការពង្រួញទៅលើសំណួររបស់ខ្ញុំបាន ។

[០៩:៥៥:៥៦]

**ឆ៖** អរគុណលោកព្រះរាជអាជ្ញា! ដែលមានអធ្យាស្រ័យខ្ពស់យល់ដល់ការចងចាំរបស់ខ្ញុំ ។ ជាងសាមសិបឆ្នាំមកហើយវាបាត់បង់ទៅ ។ អរគុណ ។ របាយការណ៍ប្រចាំថ្ងៃគេឲ្យមកខ្ញុំជាក្រដាស មានពិត ។ ថ្ងៃនេះឈឺប៉ុន្មាន? ធ្វើការប៉ុន្មាន? ជាគោលការណ៍ អង្គាល់នៅសមរភូមិគេធ្វើរបាយការណ៍នេះដើម្បីឲ្យមេបញ្ជាការណែនាំទៅវិញ ។ ក៏ប៉ុន្តែ ជាក់ស្តែងរបាយការណ៍អស់នេះ ខ្ញុំអត់ដែលណែនាំអីទៅគេទេ ។ ដូចលោកព្រះរាជអាជ្ញាជ្រាបហើយ ទីមួយ ការងារខ្ញុំជ្រែកអត់រួចទេ ច្រើន ។ ខ្ញុំឲ្យសារសំខាន់ទៅលើការចារនេះជាសំខាន់ជាង ។ ហើយទីពីរ ការងារអស់នេះគេធ្លាប់ធ្វើហើយទុកឲ្យគេធ្វើទៅចុះម្ចាស់ការ ។ នេះរបាយការណ៍ប្រចាំថ្ងៃ ។ ឯចំណែក របាយការណ៍ប្រចាំខែអាចមានជាទៀងទាត់ ឬក៏ច្រើនខែម្តងក៏អាចមានដែរ ។ ប៉ុន្តែ ពេលនោះ របាយការណ៍ខ្លះខ្ញុំបានពិចារណា ខ្ញុំបានសរសេរ បានចារបានបញ្ជាទៅក្រោមវិញ ។ ពេលខ្លះ ខ្ញុំគ្រាន់តែមើលទៅ ហើយក៏ទុកទៅ ក៏សឹងតែថាបាន ក៏សឹងតែថាមាន ។ ដូច្នេះ មិនច្បាស់ទេ មិនដឹងថា របាយការណ៍ប៉ុន្មានខ្ញុំបានអាន ហើយបានចារ ហើយរបាយ-ការណ៍ប៉ុន្មានខ្ញុំមិនបានអាន មិនបានចារ ។

ដូច្នេះ ជាគោលការណ៍គេត្រូវតែគោរពមេ គេត្រូវតែរាយការណ៍ អ៊ីចឹងហើយ ។ ក៏ប៉ុន្តែ ខ្ញុំភ្លេចអស់ ដូច្នេះ បើសិនជាមានឯកសារមកខ្ញុំវាស្រួល ខ្ញុំស្រួលលាតត្រដាងបង្ហាញ រំឭកឡើងវិញ ។ នេះសូមជម្រាបប៉ុណ្ណេះដោយស្មោះ ។ នេះខ្ញុំគិតថា ខ្ញុំឆ្លើយនេះមិនទាន់គ្រប់នឹងសំណួររបស់លោកនៅឡើយទេ សូមអញ្ជើញសួរមកទៀតចុះ ។

**ស៖** សូមអរគុណច្រើន។ ខ្ញុំនឹងមិនបង្ហាញឯកសារជូនលោកទេ ដោយសារតែខ្ញុំមានរយៈដប់នាទីក្នុងការសួរលោកប៉ុណ្ណោះ ។ ប៉ុន្តែ ខ្ញុំអាចសួរលោកនូវសំណួរបីចុងក្រោយ ។ សំណួរទីមួយទាក់ទងទៅនឹងការកម្ទេចនិងសម្លាប់នៅព្រៃស លោកមានអំណាចពេញដៃទៅលើ ហ៊ា និង ហ៊ុយស្រែ ហើយ

លោកត្រូវបានគេប្រាប់អំពី ថាតើការសម្លាប់នោះ ត្រូវធ្វើឡើងនិងកើតឡើងពេលណា? ប៉ុន្តែ លោកមិនបានចាត់វិធានការអ្វីទាំងអស់ក្នុងការបញ្ឈប់ទៅលើការកម្ទេច និងការសម្លាប់ទាំងអស់នោះក្នុងអំឡុងពេលបីឆ្នាំ ។ តើលោកអាចជម្រាបថា មែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! សំណួរលោកច្បាស់ណាស់ សូមឆ្លើយថា មែន ខ្ញុំអត់បានបញ្ឈប់មែន ។

**ស៖** ខ្ញុំនៅមានសំណួរពីរទៀត ។ ជាការពិត លោកបានចេញបញ្ជាសម្លាប់ជាដរាបទៅដល់ ហ៊ុយ ស្រេ និងហ៊ី ហើយឲ្យពួកគេធ្វើការអនុវត្តន៍ក្នុងលក្ខណៈចាំបាច់ចំពោះការងារនៅព្រៃស ។ តើមែន ឬក៏មិនមែន? ហើយខ្ញុំត្រូវតែនិយាយថាតើ បញ្ជាថាអចិន្ត្រៃយ៍អំណាចដែលលោកប្រគល់ បញ្ជាដែលលោកប្រគល់អចិន្ត្រៃយ៍នោះយ៉ាងម៉េច? ខ្ញុំនឹងពន្យល់ទៅលើចំណុចនេះ ។

[១០:០០:០០]

**ឆ៖** ខ្ញុំក្តាប់ន័យសំណួររបស់លោកមិនបានទេ សូមទោស! សូមមេត្តាសួរម្តងទៀត ។

**ស៖** ខ្ញុំពិនិត្យមើលទៅអ្នកទាំងអស់គ្នាប្រហែលជាគេអត់យល់ដែរ អ៊ីចឹង ប្រហែលជាមកពីខ្ញុំសួរហើយមើលទៅ ។ ដោយលោកផ្តល់សិទ្ធិអំណាចឲ្យ ហ៊ី ហើយនិង ហ៊ុយ ស្រេ ដើម្បីសម្រេចថាតើកំហុសប្រភេទណាដែលចាំបាច់និងបណ្តាលឲ្យពួកគេត្រូវបានបញ្ជូនទៅសម្លាប់នៅជើងឯក ពីព្រៃស? ក្នុងការផ្តល់អំណាចបែបនេះ នោះគឺជាអំណាចដែលប្រគល់ឲ្យតែម្តងទៅគឺបានហើយ មានន័យថា លោកមិនចាំបាច់ចេញបញ្ជាផ្តល់អំណាចនេះឲ្យគាត់ជារៀងរាល់ថ្ងៃក្នុងរយៈពេលពីរបីឆ្នាំនោះទេ? មានន័យថា នៅពេលដែលលោកផ្តល់អំណាចតែម្តងនោះ គឺគេយល់ថាគេមានសិទ្ធិអំណាចក្នុងការអនុវត្តជារៀងរហូតនោះ តើមែនទេ?

**ឆ៖** ច្បាស់ៗ ។ ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា សំណួរលោកច្បាស់ហើយ ។ អំណាចនេះប្រគល់ម្តងជាការស្រេច ខ្ញុំមិនសម្រេចប្រចាំករណីនីមួយៗទេ ។ សូមអរគុណ ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ ដូច្នេះបើសិនជាយើងពិនិត្យមើលការសម្លាប់អ្នកទោសនៅព្រៃស ដែលត្រូវបានគេបញ្ជូនទៅជើងឯកនោះ គឺមានន័យថា លោកមិនអាចនិយាយថាអ្នកនៅក្រោមបង្គាប់របស់លោកបានចេញបញ្ជា-- មេរបស់លោកបានចេញបញ្ជាឲ្យលោកធ្វើដូច្នោះទេ ប៉ុន្តែនោះគឺជាការចេញបញ្ជាពីខ្លួនលោក បញ្ជាឲ្យទៅ ហ៊ី ហើយនិង ហ៊ុយ ស្រេ ដើម្បីធានាថា អ្នកទោស ឬក៏អ្នក

ជាប់ឃុំនៅព្រៃសនោះឯង គឺត្រូវបានសម្លាប់ ពីព្រោះលោកគឺប្តេជ្ញាចិត្តក្នុងការអនុវត្តនូវមនោគមវិជ្ជាដ៏ឧក្រិដ្ឋ

របស់បក្សកុម្មុយនីស្តកម្ពុជា ។ តើសំណួររបស់ខ្ញុំនេះលោកយល់ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំសុំសាកល្បងឆ្លើយ បើខុសសូមលោកសួរមកម្តងទៀតចុះ ។ មាគ៌ាឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា ខ្ញុំទទួលខុសត្រូវទាំងស្រុង ក៏ប៉ុន្តែក្នុងរឿងការអនុវត្តជាក់ស្តែង គេ ។ ថ្វីត្បិតតែគេអនុវត្តជាក់ស្តែងមែន តែខ្ញុំជាម្ចាស់មាគ៌ានេះជំនួសមុខបក្ស ។ ខ្ញុំទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនេះ ។

[១០:០៣:០២]

**លោក វីល្យៀម ស្មីត៖**

សូមអរគុណលោក កាំង ហ្គេកអ៊ាវ យើងខ្ញុំពេញចិត្តចំពោះភាពស្មោះត្រង់របស់លោក និងការបញ្ជាក់ច្បាស់ៗរបស់លោក ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តនេះដល់វេទិកាមេធាវីអ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយជាដំបូងនេះ សូមអញ្ជើញមេធាវីអ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ អាចឡើងធ្វើការសំណួរសួរចំពោះជនជាប់ចោទ សូមអញ្ជើញ ។ លោកមេធាវីមានអំឡុងពេលដប់ប្រាំមីនុតក្នុងការសួរដេញដោលនេះ ។

**លោក អាឡាំង វែនណឺ៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមជូនដំណឹងដល់លោក លោកស្រីចៅក្រមថា ត្រឹមត្រូវហើយគឺមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទន្ទឹងរង់ចាំការសួរសំណួរនេះណាស់ ហើយយើងបានធ្វើការបែងចែកពេលវេលា។ ដូច្នេះ ក្រុមនីមួយៗគឺមានរយៈពេលដប់ប្រាំនាទីក្នុងការបែងចែកដើម្បីសួរសំណួរនេះ ។ ហើយដំបូង ខ្ញុំឲ្យសហសេវិករបស់ខ្ញុំគាត់ឡើងនិយាយមុន ។ សូមអរគុណលោកប្រធាន ។

**សួរដោយ កញ្ញា ទី ស្រ៊ីនណា៖**

**ស៖** សូមអរគុណលោកប្រធាន ដោយសារតែពេលវេលាមានរយៈពេលខើច អ៊ីចឹង នាងខ្ញុំសូមចាប់ផ្តើមសួរសំណួររបស់នាងខ្ញុំតែម្តង ។ ទាក់ទងនឹងសំណួរទីមួយ នាងខ្ញុំចង់សួរថា តើការដែលលោក

ស្នើសុំតំបន់បាគូ ដែលលោកលើកឡើងពីម្សិលមិញ គឺជាគំនិតផ្តួចផ្តើមរបស់លោកផ្ទាល់ ឬក៏យ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញាមេធាវី! ជាគំនិតផ្តួចផ្តើមរបស់ខ្ញុំ ។

*(អ្នកបកប្រែ៖ សូមមេធាវីដើមបើកមេក្រូហ្វូន)*

**ស៖** ទាក់ទងទៅនឹងទីតាំងព្រៃស តើនៅក្នុងទីតាំងព្រៃសហ្នឹងមានការជីករណ្តៅដើម្បីធ្វើការកប់សាកសពដែរឬទេ?

**ឆ៖** ខ្ញុំសូមឆ្លើយមួយម៉ាត់ទៅចុះ ខ្ញុំមិនច្បាស់ទេ ។ ក៏ប៉ុន្តែ បើតាមគោលការណ៍ដែលខ្ញុំណែនាំគ្មានកន្លែងកប់សាកសពនិងប្រហារជីវិតនៅព្រៃសទេ ។

**ស៖** ពីម្សិលម្ង៉ៃ ក៏ដូចជាម្សិលមិញ លោកបាននិយាយថា លោកបានទៅកាន់តំបន់ជើងឯកម្តងហើយនិងបានទៅកាន់ព្រៃសបួនទៅប្រាំលើក ។ ពេលដែលលោកទៅដល់ទីនោះ លោកបានឃើញទិដ្ឋភាពនៅទីនោះ ពេលនុ៎ងតើលោកមានដែលគិតថាលោកបានប្រព្រឹត្តអំពើខុសឆ្គងចំពោះអ្នកទោសនៅទីនោះដែរ ឬមួយយ៉ាងម៉េច?

[១០:០៦:៥៨]

**ឆ៖** ជម្រាបប្រសាសន៍កញ្ញាមេធាវី! ជីវិតមនុស្សដែលយើងផ្ទាល់ ឬប្រយោលបានបញ្ជាទៅគេឲ្យសម្លាប់ បានបញ្ជាទៅឲ្យគេតាមដាន បានបញ្ជាទៅឲ្យគេកៀបគៀត ខ្ញុំឃើញ មើលឃើញ ។ ប៉ុន្តែខ្ញុំនិយាយនេះមិនគេចកែទេ វាហួសសមត្ថភាពខ្ញុំនឹងទប់ទល់ ម្ល៉ោះហើយមានតែយកទស្សនៈមួយមកលួងចិត្តខ្លួនថា គេជារដ្ឋាភិបាល គេទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រចុះ ។ ពេលនោះខ្ញុំគិតថាប្រវត្តិសាស្ត្រខ្ញុំមិនជឿថា បក្សកុម្មុយនីស្តកម្ពុជាចាញ់ទេ ។ ដូច្នេះ ខ្ញុំជាប៉ូលិស គេឲ្យធ្វើអីធ្វើហ្នឹង ប៉ូលិសគោរពរដ្ឋាភិបាល ខ្ញុំគិតអង្កាល់នុ៎ងយល់អ៊ីចឹង ទោះបីឃើញឧក្រិដ្ឋកម្មបែបណាក៏មិនតវ៉ានឹងគេដែរ ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមបន្តទៀត ចុះនៅពេលដែលលោកត្រលប់មកវិញ នៅពេលដែលត្រលប់មកវិញ តើលោកមានដែលបានគិតគូរ ឬក៏តាំងចិត្តនៅក្នុងការព្យាយាមកាត់បន្ថយសកម្មភាពកាប់សម្លាប់នោះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញាដោយត្រង់ អត់ទេ គិតតែធ្វើម៉េចពុះពារឲ្យរស់ កុំឲ្យស្លាប់ខ្លួនឯង ។ ប៉ុននុ៎ងឯង ។ គេឲ្យធ្វើអីធ្វើហ្នឹង ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមបន្តសំណួររបស់ខ្ញុំតទៅទៀត ម្សិលមិញ លោកបាននិយាយថា នៅថ្ងៃទី៦ ខែ១ ឆ្នាំ១៩៧៩ គឺលោកបានរត់ៗចេញពីភ្នំពេញដោយសារការវាយប្រហាររបស់ទ័ពវៀតណាម ពេលនុ៎ងលោកបាននិយាយថាមានអ្នកទោសដែលនៅសេសសល់មួយចំនួន ដែលបានទៅជាមួយលោក តើមែនឬទេ?

**ឌ៖** ជម្រាបប្រសាសន៍កញ្ញា! ខ្ញុំរត់ចេញពីភ្នំពេញត្រឹមត្រូវហើយ បាតជើងសព្រាតមានតែខោខ្លីមួយចង្កេះទេ នៅម៉ោងពីរថ្ងៃ៧ មករា ១៩៧៩ ។ នៅក្នុងនោះ ដោយឡែកខាងភ្នំពេញឯនេះ មានអ្នករត់ទៅជាមួយនឹងខ្ញុំ ។ ក៏ប៉ុន្តែ មានអ្នកនៅសល់ដែរ មាន១អ្នកនៅសល់តែអ្នកនៅសល់ហ្នឹងតាមរូបថតដែលខ្ញុំឃើញមកទេ ខ្ញុំស្គាល់មកទេ ខ្ញុំស្គាល់មកខ្លះ ។ តាមរូបថតដែលខ្ញុំបានឃើញប្រាំបួននាក់សល់នៅភ្នំពេញហើយមានអ្នកទៅតាមជាមួយនឹងខ្ញុំខ្លះដែរ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

[១០:០៩:៥១]

**ស៖** ចំពោះអ្នកដែលទៅជាមួយលោក តើគឺគេទៅដោយស្ម័គ្រចិត្ត ឬមួយក៏ទៅដោយមានការបង្ខំដោយមានយកអាវុធដើម្បីគំរាមឲ្យគេទៅជាមួយ?

**ឌ៖** ខ្ញុំមិនឃើញនឹងភ្នែកទេ ក៏ប៉ុន្តែគេទៅជាមួយនឹងខ្ញុំដោយជាមួយនឹងខ្ញុំ ។ ដូច្នេះ អាវុធកាលនោះ វាស្ងួនស្ងោមិនមាននរណាបានទៅបង្ខំអ្នកណាទេ ។ នេះតាមដែលខ្ញុំមើលពេលនុ៎ង សភាពការណ៍ពេលនុ៎ង វាស្ងួនស្ងោ គ្មានអ្នកណាបង្ខំអ្នកណា ឬយ៉ាងម៉េចទេ ។ នេះខ្ញុំចាំអ៊ីចឹង ។

**ស៖** សូមអរគុណ ។ ខ្ញុំមានមួយសំណួរទៀត នេះគឺជាសំណួរចុងក្រោយរបស់ខ្ញុំ ខ្ញុំចង់សួរថាការដឹងខ្លួន និងការសុខចិត្តទទួលនូវកំហុសរបស់លោកផ្ទាល់ទៅលើអំពើឧក្រិដ្ឋកម្មរបស់លោកកាលពីសម័យកម្ពុជាប្រជាធិបតេយ្យ តើកើតមាននៅពេលណា? នៅពេលបច្ចុប្បន្ន ឬក៏កើតមាននៅពេល កាលពីសម័យមុន?

**ឌ៖** ជម្រាបប្រសាសន៍កញ្ញា! មនុស្សយើងមិនមែនល្ងង់ មិនមែនទៅឃោរឃៅដាច់ខាតមើលមិនស្គាល់ថាខ្លួនឯងបានប្រព្រឹត្តបទឧក្រិដ្ឋទេ ដឹង ។ ក៏ប៉ុន្តែ ពេលនោះដើម្បីលួងចិត្តយើងឆ្លើយទម្លាក់ថាយើងជាប៉ូលិស គេជារដ្ឋាភិបាល គេទទួលខុសត្រូវ ។ នេះជាពាក្យដែលគេនិយាយខ្ញុំ និយាយជាមួយនឹងខ្ញុំនៅពេលប្រគល់តួនាទីជាប្រធានម-១៣ ឲ្យខ្ញុំកាន់កាប់ ។ គេអ្នកសម្រេចឲ្យចាប់អ្នកណាមកឲ្យមិត្តសួរចម្លើយ គេទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រ នេះគឺយើងខ្ញុំនៅរក្សាពាក្យនេះ ។ រួចមកដល់ពេលមកឃើញមនុស្សស្លាប់ច្រើនពេក ដូចខ្ញុំនិយាយប៉ុន្មានថ្ងៃមុនហ្នឹង ខ្ញុំមានការឈឺចាប់ ខ្ញុំមានការតក់ស្លុត

ខ្ញុំមានការអធិដ្ឋាន សុំខមាលទោសចំពោះវិញ្ញាណក្ខន្ធទាំងអស់ដែលបាត់បង់នៅកម្ពុជា ។ ជាទូទៅ ដែលបាត់បង់នៅស-២១ ។ និយាយដោយឡែក ខ្ញុំនៅតែមានស្មារតីក្តុកក្តួលអ៊ីចឹង ។

ក៏ប៉ុន្តែ ចំពោះមុខច្បាប់ ខ្ញុំនៅតែតាំងខ្លួនថា ខ្ញុំប៉ូលិស គេនៅទទួលខុសត្រូវចំពោះប្រវត្តិសាស្ត្រអ៊ីចឹង ។ នៅតុលាការយោធា ខ្ញុំរាយការណ៍ទាំងអស់ ជួបជាមួយនឹងអ្នកកាសែតអ៊ីតាលី ឈ្មោះ *ប៉េលីចារ៉ូវ៉េលឡារីយ៉ូ* ក៏ខ្ញុំរាយការណ៍អ៊ីចឹង ។ ជួបទូរទស្សន៍ជប៉ុនក៏ខ្ញុំរាយការណ៍អ៊ីចឹង ជួបទូរទស្សន៍អ៊ីតាលីក៏ខ្ញុំរាយការណ៍អ៊ីចឹង ខ្ញុំប៉ូលិស គេរដ្ឋាភិបាលគេទទួលខុសត្រូវ ។ ខ្ញុំមិននេះទេ ។ ដល់មក អ.វ.ត.ក យើងមេធាវីទាំងពីរ គុណមេធាវីទាំងពីរជួយពន្យល់ឲ្យចេះសារភាពច្បាស់លាស់ ។ ឥឡូវខ្ញុំវាមានដំណាក់នេះមួយ និយាយការពិតនៅតែដដែលទេ និយាយ ។ រឿងអីដែលខ្ញុំនឹកឃើញប៉ុន្មានខ្ញុំនិយាយឡើងវិញទាំងអស់ បើកាលណាមានឯកសារថែម ខ្ញុំកាន់តែយល់ថែម ក៏ប៉ុន្តែស្មារតីគឺមិនទម្លាក់ទៅលើរដ្ឋាភិបាលដូចមុនទេ ខ្ញុំទទួលស្គាល់ថា ខ្ញុំជាបុគ្គលឧក្រិដ្ឋម្នាក់ក្នុងចំណោមឧក្រិដ្ឋជនទាំងឡាយនោះ ។ នេះខ្ញុំមានការប្រែប្រួលអ៊ីចឹង ។ សូមបញ្ជាក់ជូនវែងតិច សូមទោស ។

[១០:១៣:០៦]

**កញ្ញា ទី ស្រ៊ុនណា៖**

សូមអរគុណចំពោះការដែលលោកខំព្យាយាមឆ្លើយនឹងសំណួររបស់ខ្ញុំ ។ ខ្ញុំសូមអស់សំណួរប៉ុណ្ណឹង ។ ហើយនិងសូមបន្តសំណួរតទៅទៀត ប៉ុន្តែសំណួរហ្នឹងគឺមេធាវីអន្តរជាតិនៅក្នុងក្រុមខ្ញុំ គាត់នឹងធ្វើការបន្តសំណួរ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ។

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

លោកប្រធាន! នាឡិកាស្ទីសរបស់ខ្ញុំហ្នឹង បង្ហាញថាខ្ញុំនៅសល់ប្រាំនាទីកន្លះទៀត ។ ដូច្នេះខ្ញុំនឹងព្យាយាមសួរសំណួរតែទៅលើប្រធានបទតែមួយប៉ុណ្ណោះទៅលើរយៈពេលប្រាំនាទីកន្លះនេះ ។ អ៊ីចឹង ខ្ញុំចង់សួរទៅលើចំណុចមួយដែលខ្ញុំគិតថា មិនទាន់ត្រូវបានសួរនៅឡើយ ឬមួយក៏បានសួរដែរ។ ប៉ុន្តែ មិនទាន់បានលម្អិត គឺបានបញ្ជូនបុគ្គលិពីស-២១ ទៅព្រៃស ។

**ស៖** លោកបានផ្តល់បទសម្ភាសន៍នៅចំពោះសហចៅក្រមស៊ើបអង្កេត ដែលខ្ញុំអត់មានពេលអានលម្អិតទេ ខ្ញុំគ្រាន់តែសង្ខេបប្រាប់លោកនូវអ្វីដែលលោកបាននិយាយនៅពេលនោះ ។ នៅថ្ងៃទី៣០

ខែមេសា ឆ្នាំ២០០៨ គឺលេខយោងD71 ទំព័រ២ និង៣ ជាសង្ខេបនោះ លោកនិយាយថា នៅពេលដែលសាច់ញាតិ ឬក៏មិត្តភក្តិជិតស្និទ្ធរបស់អ្នកធ្វើការនៅស-២១ គេក៏នឹងបញ្ជូនទៅស-២១ ដែរ ។ ករណីដូចជា ស៊ូ ម៉េត ដែលគាត់ធ្វើការនៅ ស-២១ ហើយពេលហ្នឹងបងប្អូនប្រុសគាត់ ហើយនិងសាច់ថ្លៃរបស់គាត់ក៏ត្រូវបានចាប់ខ្លួនដែរ ហើយត្រូវបានបញ្ជូនទៅព្រៃស ។ តើលោកអាចបញ្ជាក់បានថា រឿងហេតុនេះកើតឡើងពិតមែន ឬក៏យ៉ាងម៉េច?

**ឆ៖** អរគុណលោកមេធាវី ខ្ញុំទទួលស្គាល់ដដែលទេ អត់ប្តូរទេ ។

**ស៖** សូមអរគុណ ។ ជាសង្ខេបទៅតាមការយល់ដឹងរបស់លោក តើរឿងហេតុបែបហ្នឹង ព្រឹត្តិ-ការណ៍បែបហ្នឹងកើតឡើងប៉ុន្មានដង ដែលថាសមាជិករបស់បុគ្គលិក ស-២១ ត្រូវបានបញ្ជូនទៅព្រៃសនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំមិនចាំទេ ប៉ុន្តែខ្ញុំគ្រាន់តែសូមលើកបញ្ហាមួយមកជម្រាប ។ មិត្ត តយ តេង ដែលទទួលភារៈនៅជីករណ្តៅជីកអីនៅជើងឯកនេះ ជាបងប្អូនជីដូនមួយជាមួយនឹងមិត្តពីរនាក់ទៀត ។ គាត់ត្រូវគេបញ្ជូន-- គាត់ត្រូវពួកខ្ញុំបញ្ជូនទៅឲ្យជីករណ្តៅ ផុតពីការងារជាកងពិសេសនៅឯភ្នំពេញនេះ ។ ដូច្នេះ វាមានច្រើនអីចឹង១ ។ នេះមួយករណីដែលជាប់បងប្អូន ។ ករណីទីមួយដែលជាប់បងប្អូន សូមជូនឧទាហរណ៍ពីរហ្នឹង មានករណីផ្សេងទៀត ។

**ស៖** ខ្ញុំចង់និយាយនូវចំណុចខាងក្រោមនេះប្រាប់លោក នៅពេលដែលលោកនិយាយជាមួយសហចៅក្រមស៊ើបអង្កេត គឺនៅថ្ងៃទី១៨ ខែ០១ ២០០៨ គឺនៅទំព័រ៨ និង៩ ។ លោកនិយាយប្រាប់សហចៅក្រមស៊ើបអង្កេតថា រឿងហេតុដូច្នេះគឺបានកើតនៅចំពោះមុខលោកដែរ គឺសមាជិករបស់គ្រួសារលោកត្រូវបានចាប់នៅស-២១ គឺជាបង ឬក៏ប្អូនថ្លៃរបស់លោកនោះ ។ ពេលដំបូងលោកព្យាយាមជួយគាត់ ដោយសរសេរលិខិតសម្ងាត់ទៅ សុន សេន ដើម្បីកុំឲ្យចាប់បងប្អូនថ្លៃរបស់លោកនោះ ។ ហើយចុងបញ្ចប់ នួន ជា បានចេញបញ្ជាឲ្យចាប់ខ្លួនបង ឬក៏ប្អូនថ្លៃរបស់លោកនោះ ។ ហើយបន្ទាប់មកទៀត គឺគាត់ត្រូវបានគេបញ្ជូនមកស-២១ ។ តើលោកអាចបញ្ជាក់បានទេ ត្រង់ចំណុចនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី រឿងដែលខ្ញុំអាចគិតថាការបកប្រែច្រឡំត្រង់តែមួយម៉ាត់ទេថា ខ្ញុំសរសេរសំបុត្រទៅលោកគ្រូ សុន សេន ខ្ញុំអត់បានសរសេរទេ១ ។

[១០:១៨:១៨]

ក៏ប៉ុន្តែ គោលការណ៍ដែលខ្ញុំចង់ការពារប្អូនខ្ញុំ មែន ។ ដល់ក្រោយមកពូ នួន បញ្ហាមែន ។ ខ្ញុំសូមលើសសំណួរលោកមេធាវីបន្តិចទៅចុះៗ បានទេ?

**ស៖** ដោយសារពេលវេលារបស់ខ្ញុំហ្នឹងវាអស់ហើយ ។ ហើយខ្ញុំមានសំណួរពីរចុងក្រោយទៀតដែលខ្ញុំត្រូវសួរ អ៊ីចឹងខ្ញុំយល់អ្វីដែលលោកបាននិយាយហើយ គឺថាបងប្អូនថ្លៃរបស់លោកត្រូវបានគេបញ្ជូនទៅ ស-២១ គឺវាមានច្បាប់ដែលថាបុគ្គលិករបស់ស-២១ មានសមាជិកគ្រួសារ ហើយសមាជិកហ្នឹងគឺនឹងត្រូវបញ្ជូនទៅស-២៤ ។ ហេតុអ្វីបានជាសមាជិករបស់លោកមិនត្រូវបានគេបញ្ជូននោះនៅពេលដែលបងប្អូនប្រុសថ្លៃរបស់លោកនោះត្រូវបានគេបញ្ជូនទៅស-២១? តើលោកអាចពន្យល់អំពីចំណុចនេះបាទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវីៗ! បញ្ហាហ្នឹងហើយដែលខ្ញុំចង់បញ្ជាក់ថែមជូនលោក ។ ក្នុងៗវង្សត្រកូលខ្ញុំ ខ្ញុំជាបង្គោលៗ ក្នុងបក្សកុម្មុយនីស្តកម្ពុជា ខ្ញុំជាបង្គោលរបស់គ្រួសារខ្ញុំ ។ បើគេចាប់ខ្ញុំ អស់ហើយគ្មានសល់ទេ ។ គេចាប់ប្អូនខ្ញុំ ប្អូនវាបុគ្គលបន្ទាប់បន្សំទេ គេចាប់ប្អូនថ្លៃខ្ញុំ ប្អូនថ្លៃខ្ញុំជាបុគ្គលបន្ទាប់បន្សំទេក្នុងគ្រួសារខ្ញុំ ។

**ស៖** លោកប្រធាន ។ សូមទោសខ្ញុំអាចសូមតែមួយនាទីទៀតទេ សម្រាប់សំណួរចុងក្រោយ ។ សូមអរគុណ ។

ខ្ញុំសូមលើកឡើងនូវចំណុចដូចខាងក្រោមនេះ ។ យើងគឺ មើលទៅដូចជាទិដ្ឋភាពដូចគ្នាពីម្សិលមិញអ៊ីចឹង ទាក់ទងទៅនឹងចម្លើយសារភាពរបស់ កែ គឹមហួត ហើយនិង វន វ៉េត ដែលលោកបាននិយាយកាលពីម្សិលមិញ ហើយដែលពាក់ព័ន្ធនឹងលោក ។ ដូច្នេះសម្មតិកម្មរបស់យើងដូចខាងក្រោមនេះ ខ្ញុំចង់លើកឡើងថា ខ្ញុំលើកឡើងនៅចំណុចខាងក្រោម ដើម្បីឲ្យលោកផ្ដល់មតិមកវិញ ។ អ្វីទៅក៏ដោយដែលជាការសម្រិតសម្រាំង ឬក៏ការជម្លៀសដែលបានកើតឡើង ឬក៏ការចូលរួមរបស់លោកផ្ទាល់តាមរយៈការសារភាព ឬក៏សមាជិករបស់អ្នកដែលត្រូវគេបញ្ជូនទៅស-២១ នោះ គឺមិនដែលមានរឿងអ្វីកើតឡើងដល់ខ្លួនលោកផ្ទាល់ទេ គឺមានន័យថា គ្មានអ្នកហ៊ានប៉ះពាល់លោកទេ ពីព្រោះគឺ សុន សេន និង នួន ជា ជាអ្នកការពារលោក ពីព្រោះគេពេញចិត្តនឹងភាពក្លាហានរបស់លោក ជាពិសេសទាក់ទងទៅនឹងការធ្វើបញ្ជីខ្មាំង ដែលលោកបានធ្វើឲ្យទៅពួកគាត់នោះ ។ តើលោកព្រមព្រៀងជាមួយនឹងសម្មតិកម្មនេះដែរឬទេ?

[១០:២១:៥៧]

**ឆ៖** អរគុណលោកមេធាវីៗ ខ្ញុំនៅរស់ដោយសារបញ្ហាអស់នេះ វាជាការពិត ។ ក៏ប៉ុន្តែ បញ្ហាសំខាន់ដែលយើងខ្ញុំមើលត្រឡប់ទៅក្រោយវិញ គឺខ្ញុំស្មោះត្រង់នឹងគេដាច់ខាត ស្មោះត្រង់ដាច់ខាត គេមើលមកឃើញខ្ញុំស្មោះត្រង់ដាច់ខាត ។ បើនិយាយថា *អាំងទូសហ្សាប* មិនមែនទេ គេមើលខ្ញុំដែរ គេតាមដានខ្ញុំតទៅទៀតដែរ ។ គេមានការមិនជឿទុកចិត្តប៉ុន្មានដែរ ។ នេះខ្ញុំសូមជម្រាបប៉ុណ្ណេះ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណដែលបានឆ្លើយនឹងសំណួររបស់ខ្ញុំ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ឥឡូវហ្នឹងដល់វេទិកាមេធាវីក្រុមពីរ ប៉ុន្តែ មុននឹងបញ្ជូនជូនទៅដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ។ ខ្ញុំសូមរំឭកដល់ជនជាប់ចោទថា សូមប្រុងប្រយ័ត្នក្នុងការប្រើនូវរហស្សនាមសាក្សីដែលមានការពាក់ព័ន្ធនៅក្នុងរឿង ។ ពីព្រោះសាក្សីទាំងអស់នោះត្រូវបានទទួលវិធានការការពារ យើងអត់ទាន់សម្រេចទេមុនពេលធ្វើសវនាការលើគាត់ ។ អ៊ីចឹង សូមអាចបើចំអ្នកដែលត្រូវជាសាក្សី ឬក៏ជាអ្នកដែលពាក់ព័ន្ធនៅក្នុងរឿងនោះ សូមប្រើរហស្សនាម ដែលយើងបានចែកជូនរួចហើយ ។

ជាកិច្ចបន្តសូមអញ្ជើញ មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ។ មានសំណួរអ្វីចង់សួរជនជាប់ចោទទេ? សូមអញ្ជើញ ។

**សួរដោយលោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

អរុណសួស្តី លោក លោកស្រីចៅក្រម យើងមានសំណួរមួយចំនួន ហើយខ្ញុំតំណាងក្រុមទីពីរ ខ្ញុំគិតថា ខ្ញុំអាចសួរសំណួរទាំងអស់នេះរបស់ខ្ញុំមុនពេលឈប់សម្រាក ។ តើនេះខ្ញុំលើកឡើងនេះត្រឹមត្រូវដែរឬទេ? សូមអរគុណ ។ សំណួររបស់ខ្ញុំមានដូចតទៅ៖

**ស៖** លោកបានប្រាប់យើងថា ពួកសមាសភាព គឺជាពាក្យដែលគេប្រើជាផ្លូវការ ហើយលោកក៏បានរៀបរាប់យើងផងដែរថា ពួកសមាសភាពនោះ គឺបាត់បង់សិទ្ធិស៊ីវិលរបស់គាត់ ។

តើវាត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា ត្រឹមត្រូវហើយ ។

**ស៖** សូមអរគុណ ។ សំណួររបស់ខ្ញុំបន្តទៀត ថាតើពាក្យនេះវាស៊ីគ្នា និងស្របគ្នាជាមួយនឹងពាក្យ "អា" ដែរឬទេ ដែលគេត្រូវបានប្រើជាមួយនឹងខ្មាំងនោះ? ឬក៏មានពាក្យណាមួយ ដែលមានវា

លក្ខណៈថោកទាប ដែលត្រូវបានប្រើប្រាស់ចំពោះពួកសមាសភាព ដើម្បីបន្ថែមទៅលើភាពមិនថ្លៃថ្នូរ ទៅលើពាក្យដែលថា "អា" នោះ?

[១០:២៦:០៨]

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! ពាក្យ"អា" ពាក្យ "មេ" ជាពាក្យដែលប្រើចំពោះសត្វ ហើយនិងចំពោះខ្មាំង ត្រឹមត្រូវ ។ ក៏ប៉ុន្តែជាមួយនឹងពួកសមាសភាព គេអត់ទាន់ប្រើពាក្យ "អា" និងពាក្យ "មេ" ទេៗ ។ ក៏ប៉ុន្តែ គ្រាន់តែគេមិនទុកឲ្យគាត់មានសិទ្ធិស្មើនឹងគេ ។ នេះប៉ុណ្ណឹង ។

**ស៖** សូមអរគុណ ។ សំណួររបស់ខ្ញុំបន្ទាប់ទៀត ទាក់ទងទៅនឹងចំណុចដែលថា ថាតើពាក្យ "សមាសភាព" នេះ គឺមានមុខនាទីនិងតួនាទីដូចនឹងពាក្យ "ខ្មាំង" ដែរឬទេ? បានន័យថា នៅពេលដែលខ្ញុំមានន័យថាមានមុខនាទីដូចគ្នានេះ គឺគេប្រើពាក្យនេះដើម្បីជួយសម្រួលទៅដល់បុគ្គលិក ដើម្បីឲ្យបុគ្គលិកអាចធ្វើការវាយតប់ សួរចម្លើយ និងធ្វើទារុណកម្ម ។ អ៊ីចឹងពាក្យគឺប្រើសម្រាប់សម្រួលការងារនេះដែរឬទេ? ថាតើវាមានតួនាទីស្រដៀងគ្នាដែរឬទេ នៅក្នុងការប្រើពាក្យនេះក្នុងការអនុវត្តការងារដូច្នោះ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! ពាក្យ "សមាសភាព" នេះខ្ញុំបានបញ្ជាក់ហើយ មានន័យថាមនុស្សនុំង មួយកំណាត់ជាខ្មាំង មួយកំណាត់ជាមិត្ត មិនទាន់ច្បាស់ជាខ្មាំង ឬមិត្ត ។ ពាក្យនេះ ក្នុងការអនុវត្តមានន័យធ្ងន់ជាង ពាក្យថាប្រជាជន១៧ មេសា បន្តិចៗ ។

**ស៖** តើខ្ញុំអាចសួរលោកដែរឬទេថា ថាតើវាមានភាពងាយស្រួលសម្រាប់បុគ្គលិកនៅស-២១ នៅពេលដែលបុគ្គលិកទាំងអស់នោះ ហៅពួកនោះថា ពួកសមាសភាព ។ ហើយដូច្នេះ នៅពេលហៅដូច្នេះពួកគេអាចធ្វើការប្រព្រឹត្តទៅលើពួកគេ ដោយមានភាពងាយស្រួល ។ វាមានភាពងាយស្រួលក្នុងហៅពួកទាំងអស់នោះ ថាពួកសមាសភាព ។

**ឆ៖** ត្រឹមត្រូវៗហើយ ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមចូលទៅដល់ចំណុចមួយទៀត តើលោកបានដឹងដែរឬទេ ថានៅពេលថា-- គឺមានការរៀបការជាក្រុមត្រូវបានធ្វើឡើង នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា ខ្ញុំសូមនិយាយបញ្ហានេះវែងបន្តិច ។ នៅភ្នំពេញខ្ញុំមិនដែលឃើញគេរៀបការ ដោយគ្រាន់តែប្រាប់ថាមីនេះប្រពន្ធអានេះ អានេះប្ដីមីនេះ ដូចតា ម៉ុក គាត់ធ្វើទេ មានតែតា ម៉ុកទេ ។ ខ្ញុំជាមួយនឹងប្រពន្ធខ្ញុំ ខ្ញុំស្ម័គ្រចិត្តស្រឡាញ់គេ ខ្ញុំស្រឡាញ់គេ ខ្ញុំតាមស្រឡាញ់គេប៉ុន្មានខែឯនោះ បានៗខ្ញុំដណ្ដឹង ។ ហើយដល់ទៅការ គឺខ្ញុំស្នើការ ។ ហើយជាមួយនៅក្នុងអង្គភាព ស-២១ ខ្ញុំបានការ

តែពីរគូទេ គូទីមួយគឺមិត្តប៉ុន និង មិត្តនី ។ គូទីពីរ មិត្តហ៊ា ហើយនិងមិត្តម៉ុត ។ ក្រៅពីនោះខាងអង្គភាពចាស់របស់គេ គេការឲ្យតាមការស្ម័គ្រចិត្ត ស្រីនិងប្រុសគេស្រលាញ់គ្នា ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** គឺហាក់ដូចជាមិនឆ្លើយពេញទៅលើសំណួររបស់ខ្ញុំនោះទេ ។ ខ្ញុំសួរឡើងវិញ ។ តើលោកបានដឹងដែរឬទេ (ខ្ញុំមិនសួរក្នុងករណីលោកទេ ក្នុងលក្ខណៈទូទៅ) តើលោកបានដឹងអំពីគោលនយោបាយ (ខ្ញុំសូមហៅថាគោលនយោបាយ) តើលោកបានដឹងអំពីគោលនយោបាយនៃការរៀបការជាក្រុមត្រូវបានគេធ្វើឡើង និងរៀបចំឡើងដោយអង្គការដែរឬទេ? តើលោកបានដឹងអំពីការអនុវត្តបែបដូច្នេះដែរឬទេនៅក្នុងប្រទេសនេះ? ខ្ញុំសូមលើកឡើងក្នុងលក្ខណៈទូទៅ មិនមែនលើករណីជាក់លាក់ទេ ។

**ប្រធានអង្គជំនុំ៖**

មេធាវីសួរសំណួរក្រៅអង្គហេតុ ។ អ៊ីចឹង ជនជាប់ចោទ មិនបាច់ឆ្លើយនឹងសំណួរនេះទេ ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

នេះគឺជាសំណួរចាប់ផ្ដើមរបស់ខ្ញុំទេ ដោយសារតែវាពាក់ព័ន្ធនឹងសំណួរបន្ទាប់ទៀត ហើយវាពាក់ព័ន្ធទៅនឹងសំណួរស-២៤ ។ ហើយចំណុចនេះ គឺយើងបានពិភាក្សារួចហើយ ដូច្នេះហើយខ្ញុំសូមអនុញ្ញាតពីលោកប្រធាន អនុញ្ញាតឲ្យលោកជនជាប់ចោទ ធ្វើការឆ្លើយតបទៅនឹងសំណួរនេះ ដោយសារសំណួរនេះ គឺជាសំណួរផ្ដើមទាក់ទងនឹងសំណួរខាងក្រោយ ។

**ប្រធានអង្គជំនុំ៖**

មិនឲ្យសួរទៀតទេ ហើយមិនឲ្យជនជាប់ចោទឆ្លើយនឹងសំណួរទាំងឡាយណា ដែលជាសំណួរក្រៅអង្គហេតុបានចោទប្រកាន់ ។

**សួរដោយលោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

**ស៖** សំណួរបន្ទាប់ ប៉ុន្មានថ្ងៃមុនលោកបានឃើញរូបភាពទាក់ទងទៅនឹងអាហារ ការរៀបចំម្ហូបអាហារនៅក្នុងពិធីការរបស់ នុន ហ៊ុយ ។ ថាតើការរៀបការនោះ គឺជាការរៀបការលក្ខណៈជាក្រុមដែរឬទេ?

[១០:៣២:២៧]

**ឆ៖** បើតាមខ្ញុំចាំ កាលនោះ ៧០៣ ម្ចាស់អង្គភាពដើមរបស់គេទាំងពីរនាក់ ប្ដីប្រពន្ធនេះ គេរៀបការឲ្យ ។ ដល់ខ្ញុំនាំទាំងពីរនាក់ប្ដីប្រពន្ធ គេរៀបការថ្មីហ្នឹងមកជប់លៀង ដើម្បីឲ្យកម្មាភិបាលផ្សេង

ទៀតទទួលស្គាល់មិត្តខឿន ផង ។ ជប់លៀងនេះនៅផ្ទះខ្ញុំ ការគេធ្វើពិធីនៅឯ៧០៣នោះរួចហើយ តែមួយគូទេ ។

**ស៖** នៅក្នុងភាសាបកប្រែជាភាសាអង់គ្លេស គឺបាននិយាយថា វាផ្ទុយនឹងអ្វីដែលលោកនិយាយថាមានការរៀបការពីរគូនៅពេលមុន ប៉ុន្តែនៅពេលនេះថាមួយគូ ។ ថាតើលោកអាចបញ្ជាក់ដែរឬទថាតើមានប៉ុន្មានគូដែរ ដែលរៀបការនៅក្នុងពេលតែមួយ ដូចជានៅពេលការ នុន ហ៊ុយ នោះ?

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទមិនបានឆ្លើយនឹងសំណួរនេះទេ សំណួរក្រៅអង្គហេតុចោទប្រកាន់។ មេធាវីរៀបចំនូវសំណួររបស់ខ្លួនឲ្យបានត្រឹមត្រូវឲ្យចូលទៅនឹងអង្គហេតុដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ។

យើងរំឭកម្តងទៀតថា សំណួរច្រំដែល សំណួរក្រៅអង្គហេតុ សំណួរដឹកមុខ សំណួរឧបមាណវិធី សំណួរទាំងអស់នេះគឺ ហាមមិនឲ្យសួរទេ ។ ជិតអស់ម៉ោងហើយ ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្ដី៖**

ខ្ញុំមើលនាឡិកានោះ គឺថាខ្ញុំសល់ប្រាំនាទីទៀត ។ សូមអរគុណចំពោះការណែនាំ គឺខ្ញុំត្រូវការពន្យល់ដើម្បីធ្វើយ៉ាងណាបង្កើតសំណួររបស់ខ្ញុំ បើសិនបើមិនដូច្នោះទេ គឺខ្ញុំមិនអាចសួរបានទេ ខ្ញុំនឹងមិនលើកសំណួរនេះឡើងវិញទៀតទេ ។ ជាការពិត ស្ថានភាពរស់នៅរបស់បុគ្គលិក គឺបានបង្ហាញអំពីរបៀបដែលពួកគេរស់នៅស-២៤ ហើយវាបានបង្ហាញអំពីជីវិតរបស់ពួកគេរស់នៅនៅទីនោះផងដែរគឺថាជីវិតរបស់ពួកគេត្រូវបានរៀបចំដោយអង្គការ ។ នៅពេលនេះ គឺខ្ញុំសូមចូលទៅដល់សំណួររបស់ខ្ញុំបន្ទាប់មួយទៀត ។

**ស៖** តើលោកជនជាប់ចោទអាចប្រាប់ហេតុផលជូនខ្ញុំដែរឬទេដែលលោកបានពន្យល់ថា ស្ត្រីនិងបុរស នៅស-២៤ ត្រូវបានគេបំបែកចេញពីគ្នា? ថាតើត្រឹមត្រូវដែរ ឬទេ? សូមលោកបញ្ជាក់ ។

**ឆ៖** ស្ត្រីនិងបុរស បើកាលណាមិនមែនជាប្តីប្រពន្ធ ដាច់ខាតត្រូវតែនៅដាច់ពីគ្នា ។ បើកាលណាជាប្តីប្រពន្ធ អាចមានពេលជប់ថ្ងៃជួបគ្នាម្តង ។ នេះគោលការណ៍កំណត់ ។

[១០:៣៥:៥៨]

**ស៖** តើលោកអាចបញ្ជាក់ហេតុផលដែរឬទេ? លោកបញ្ជាក់អំពីហេតុផលដោយខ្លីមួយ ថា មូលហេតុអ្វីបានជាគេបំបែកអ្នកទាំងពីរនោះចេញពីគ្នា?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញាមេធាវី! ហេតុផល គឺគ្មានអីប្រមូលផ្តុំចិត្ត ថ្លើម គំនិត អារម្មណ៍ កម្លាំង ពេលវេលា ទៅបំពេញការងារជូនបក្សទេ ។ កុំឲ្យរវល់អាប្តីប្រពន្ធរវល់តែប្រឡែងគ្នានោះ ។

**ស៖** សូមអរគុណ ខ្ញុំសូមចូលទៅដល់សំណួរចុងក្រោយរបស់ខ្ញុំ ។ សំណួរនេះ គឺវាទាក់ទងទៅនឹងគោលនយោបាយទូទៅនៅព្រៃស ។ តើខ្ញុំនិយាយត្រឹមត្រូវដែរឬទេ? នូវអ្វីដែលលោកបាននិយាយកាលពីម្សិលមិញនិងនៅថ្ងៃនេះ វគ្គអប់រំ គឺដោយថា វាបន្ទាប់មកមានការអប់រំ ហើយមានការដោះលែងនោះ គឺមិនអាចមានករណីនេះកើតឡើងនោះទេ? តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញាមេធាវី! នៅស-២៤ គ្មានដោះលែងទេ ច្បាស់លាស់ណាស់ ។

**ស៖** ដូច្នេះ ខ្ញុំចង់ផ្តល់បន្ថែមចម្លើយរបស់ខ្ញុំទៅលើសំណួរនេះ ហេតុអ្វីបានជាស-២៤ មានភាពចាំបាច់ ប្រសិនបើមនុស្សទាំងឡាយត្រូវបានគេបញ្ជូនទៅសម្លាប់នៅជើងឯក និងស-២១ ហើយនោះ? ហេតុអ្វីបានជាមានយន្តការកណ្តាលមួយទៀត ដែលថា មាន ស-២៤ មួយទៀតធ្វើអ្វី?

**ឆ៖** សូមបញ្ជាក់ថា នេះជាសេចក្តីសម្រេចរបស់បក្សខាងចាត់តាំង ។ ខ្ញុំអាចគ្រាន់តែនិយាយដើម្បីយល់អំពីគំនិតរបស់គេក្នុងចាត់តាំង-- ថាឲ្យត្រូវគឺមិនត្រូវទេ ។ តាមយល់ មនុស្សនោះវាមិនទាន់មានហេតុផលគ្រប់គ្រាន់ល្មមគេសួរចម្លើយហើយកម្ទេច ។ ម្ល៉ោះហើយគេទុកៗដើម្បីពិនិត្យតទៅទៀត ចម្រាញ់សម្រិតសម្រាំងតទៅទៀត នេះខ្ញុំយល់ឃើញអ៊ីចឹង ។ នេះការយល់ដឹងរបស់ខ្ញុំទេណា៎ មិនមែនជាមាគ៌ា គេចារមកអ៊ីចឹងទេ ។ សូមបញ្ចប់ ។

**លោកស្រី ស៊ីលយ៉ឺស្ទួត ហ្សីនស្តី៖**

សូមអរគុណ ។ ខ្ញុំអស់សំណួរហើយ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ម៉ោងត្រូវសម្រាក អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរការសវនាការដេញដោលតទៅទៀត ។

*[សវនាការសម្រាកពីម៉ោង ១០:៣៩:៤០ នាទី ដល់ម៉ោង ១១:00នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលតទៅទៀត ហើយជាកិច្ចបន្តនេះ សូមប្រគល់វេទិកាជូនទៅមេធាវីអ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ហើយដើម្បីមានឱកាសក្នុងការតាំងសំណួរសួរដល់ជនជាប់ចោទ ។

សូមអញ្ជើញមេធាវីក្រុមបី ។

**សួរដោយកញ្ញា ម៉ុច សុវណ្ណារី៖**

សូមអរគុណលោកប្រធាន ជាដំបូងនាងខ្ញុំសូមគោរពដល់លោកប្រធាន ហើយនិងអង្គជំនុំជម្រះទាំងមូល ហើយសូមអរគុណលោកជនជាប់ចោទដែលព្យាយាមឆ្លើយនឹងសំណួររបស់ខ្ញុំនៅពេលបន្តិចទៀតនេះ ។ នាងខ្ញុំសំណួរតែពីរទេ ដើម្បីសួរដល់ជនជាប់ចោទ ហើយនាងខ្ញុំសូមអនុញ្ញាតលោកប្រធានដើម្បីផ្ទេរវេទិកានេះជូនដល់សហភាតារបស់ខ្ញុំនៅក្នុងក្រុមនាងខ្ញុំ ឲ្យគាត់បានបន្តសួរសំណួរ ។

**ស៖** កាលពីថ្ងៃម្សិលមិញលោកបានអះអាងថា មនុស្សដែលគេចាប់បញ្ជូនទៅមន្ទីរស-២៤ មន្ទីរអប់រំកែប្រែព្រៃស ហ្នឹង លោកបានបញ្ជាក់ថា មានវិធីមួយ គឺមុននឹងគេបញ្ជូនទៅស-២៤ ហ្នឹង គឺគេបានបញ្ជូនគាត់ទៅដាក់នៅមួយកន្លែងសិន គឺកន្លែងដែលមានអក្សរ “R” ។ តើលោកចាំបានទេ? អ៊ីចឹងនាងខ្ញុំចង់សួរថា តើនៅពេលដែលគេទុកមនុស្សទាំងអស់នោះនៅកន្លែងហ្នឹង តើគេទុកក្នុងរយៈពេលប៉ុន្មាន? ហើយគេធ្វើយ៉ាងម៉េចចំពោះអ្នកទាំងអស់នោះ មុននឹងគេបញ្ជូនទៅមន្ទីរអប់រំកែប្រែព្រៃស?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញាមេធាវី! អក្សរ“R” នេះ វានៅលើផែនទីដែលខ្ញុំគូរជូនលោកចៅក្រមស៊ើបអង្កេត ។ នៅផ្លូវលេខ៣៦០ ដែលយើងហៅថាផ្លូវមេភ្លើង ។ អក្សរ“R” ហ្នឹង ឥឡូវ ម៉ម សូណាង់ដូគាត់ទៅទិញយកមកធ្វើប៉ុស្តិ៍វិទ្យុសំបុកឃ្មុំគាត់ហ្នឹង ។ កន្លែងហ្នឹងគេទុកជាកន្លែងទទួលមនុស្ស ។ ដូច្នេះ អ្នកណាបញ្ជូនមកអក្សរ “R” ហ្នឹង ខ្ញុំដឹងមុនហើយ ខ្ញុំប្រាប់ឲ្យគេចាំទទួល ។ ដូច្នេះ អ្នកដែលជូនទៅព្រៃស ខាងនុ៎ង គេទទួលហើយ គេជូនទៅភ្លាម គេអត់ទុកយូរទេ ។ នេះ ខ្ញុំសូមឆ្លើយប៉ុណ្ណេះ ។

**ស៖** នាងខ្ញុំសូមអរគុណ ។ សម្រាប់ការផ្តល់ព័ត៌មានរបស់លោក ។ សំណួរទីពីរ ហើយក៏ជាសំណួរចុងក្រោយ ។ នៅក្នុងចិត្តរបស់លោក នៅពេលដែលលោកកាន់កាប់មន្ទីរ ស-២១ ទាំងមូលរួមទាំងព្រៃ-សផងនោះ នៅពេលនោះ តើលោកជឿថា មនុស្សដែលគេចាត់ទុកថាជាក្រុមសមាសភាពនោះពិតជាមនុស្សដែលមានគ្រោះថ្នាក់ ហើយអាចបង្កគ្រោះថ្នាក់ដល់បក្សបានមែន ឬក៏យ៉ាងម៉េច?

[១១:០៣:២៥]

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! ឲ្យជឿទាំងស្រុងមិនជឿទេៗ។ យើងនិយាយឲ្យស្រួលស្ដាប់ទៅចុះ មិនមែនមិនជឿសោះទេ យើងគិតថា ដប់ភាគរយអាចបង្កគ្រោះថ្នាក់ដល់គេ កៅសិបភាគរយគឺអត់ទេ ។

**ស៖** អ៊ីចឹងនាងខ្ញុំសូមធ្វើនូវសេចក្ដីសន្និដ្ឋានមួយ ហើយសូមលោកបញ្ជាក់ថា ការសន្និដ្ឋាននេះតើត្រឹមត្រូវដែរឬទេ? មានន័យថា នៅពេលនោះ គឺលោកជឿត្រឹមតែកៅសិបភាគរយ ប៉ុណ្ណោះថាក្រុមសមាសភាពទាំងនោះអាចបង្កគ្រោះថ្នាក់ដល់បក្ស?

**ឆ៖** ខ្ញុំសូមបញ្ជាក់ឡើងវិញ ខ្ញុំជឿត្រឹមតែដប់ភាគរយទេ កៅសិបភាគរយមិនជឿទេ ។

**ស៖** អ៊ីចឹងបានន័យថា កៅសិបភាគរយទៀត គឺលោកជឿថា គេមិនអាចបង្កគ្រោះថ្នាក់ដល់បក្សទេ ទីមួយ ។ ទីពីរ លោកមានសិទ្ធិ លោកមានអំណាចនៅក្នុងការសម្រេចអំពីជោគវាសនារបស់គេ ពីព្រោះអំណាចកម្ទេចពាក់កណ្ដាលគឺនៅលើលោក ។ ក៏ប៉ុន្តែ លោកបានជ្រើសរើសវិធី គឺលោកបានមិនយកចិត្តទុកដាក់ចំពោះការនោះ ហើយលោកសម្រេចផ្ទេរសិទ្ធិអំណាចទាំងអស់នោះ ទៅឲ្យអ្នកនៅក្រោមបង្គាប់ តើការសន្និដ្ឋានបែបនេះជាការត្រឹមត្រូវដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! ត្រឹមត្រូវហើយ ខ្ញុំផ្ទេរអំណាចហ្នឹងទៅឲ្យគេសម្រេច ។

**កញ្ញា ម៉ុច សុវណ្ណារី៖**

នាងខ្ញុំសូមអរគុណ ចំពោះការសហការរបស់លោក ។ នាងខ្ញុំសូមអនុញ្ញាតផ្ទេរវេទិកាជូនដល់សហភាគីរបស់នាងខ្ញុំ ។ សូមអរគុណ ។

**សួរដោយលោក គីម ម៉េងឃី៖**

សូមគោរពលោកប្រធាន សូមគោរពអស់លោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់នៅក្នុងអង្គសវនាការ ។ ខ្ញុំបន្តសំណួរអំពីក្រុម៣ ខ្ញុំនាំនាំនូវសំណួរពីជនរងគ្រោះរបស់យើងខ្ញុំសួរទៅកាន់លោកជនជាប់ចោទក្នុងករណីបី ។

**ស៖** ករណីទីមួយ គឺគាត់សួរថា តើមានការយកមនុស្សពីព្រៃសទៅកម្ទេចដោយសារមូលហេតុនៃការលួចផ្លែឈើ ឬក៏ដំឡូងមួយមើមដែរឬទេ? ហើយករណីទីពីរ គឺទាក់ទងទៅនឹងការឲ្យជីកប្រឡាយចំនួនបីថ្ងៃ ដោយគ្មានឲ្យអាហារ ឬម្ហូប អង្ករមួយគ្រាប់ចូលក្នុងពោះសោះ ហើយនិងបង្ខំឲ្យធ្វើការជារៀងរាល់ថ្ងៃពីម៉ោងពីព្រឹក រហូតដល់ម៉ោងប្រាំល្ងាច ហើយនិងករណីទីបី គឺប្រើដែកកេះ ដុតកែងដៃ

និងកែងជើងសម្រាប់យុទ្ធនារីដែលឈឺមិនអាចទៅធ្វើការរួច ។ តើលោកបានដឹងពីករណីទាំងបី នេះដែរឬទេ?

[១១:០៦:៣០]

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ទុក្ខសោករបស់ជនរងគ្រោះ ខ្ញុំអត់តទល់ទេ ខ្ញុំទទួល គេនិយាយមកចុះ ខ្ញុំទទួល ។ បើសិនជាខ្ញុំមិនបានបញ្ជាទេ គឺខ្ញុំមិនដឹង ដូច្នេះ ខ្ញុំមិនយកលេសមិនដឹងនេះ ដើម្បីបដិសេធទុក្ខវេទនារបស់គេ ខ្ញុំទទួលទុក្ខវេទនារបស់គេទាំងអស់ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** សូមអរគុណ ។ សំណួរបន្តមួយទៀត ក៏ជាការពាំនាំនូវសំណួររបស់ជនរងគ្រោះដដែល ពាក់ព័ន្ធទៅនឹងវិធីកម្ទេចដែលលោកបានលើកឡើងថាមិនមាន ខ្ញុំមិនបានឮថាលោកបានបង្គាប់ឲ្យមាន កម្ទេចមនុស្ស ដោយការកាត់ក្បាលមនុស្សនោះទេ ហើយហេតុដូច្នេះ សំណួររបស់ជនរងគ្រោះនោះគាត់ ចង់ដឹងថា តើករណីនេះវាអាចកើតចេញអំពីការយកមនុស្សពីព្រៃស ទៅកម្ទេចនៅជើងឯកបានទេ ដោយការកាត់កនូវមនុស្សចំនួន១៦៦នាក់ នៅមជ្ឈមណ្ឌលជើងឯក? តើមានករណីបែបនេះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! បញ្ហានេះខ្ញុំនៅឮជាព័ត៌មាន ប៉ុន្តែស្រាវជ្រាវរកប្រភពអត់ ទាន់ឃើញស្អីជាភស្តុតាង ដើម្បីខ្ញុំអះអាងថាម៉េច ដើម្បីខ្ញុំបដិសេធក៏គ្មានភស្តុតាង ដើម្បីខ្ញុំទទួលស្គាល់ នៅឡើយ ក៏គ្មានភស្តុតាងទេ ។ ព័ត៌មាននេះឮមែន ឮដល់ខ្ញុំ ហើយសូមបញ្ជាក់ថា អង្កាល់ដែលខ្ញុំនៅធ្វើ ជាប្រធាន ស-២១ ទីមួយខ្ញុំអត់បានបញ្ជាឲ្យមានការកាត់ក្បាលយកទៅណា ទុកធ្វើអីទេ នេះទីមួយ ។ ទីពីរទៀត ក៏មិនដែលឮព័ត៌មានមកដល់ខ្ញុំថា មានការសម្លាប់ហើយកាត់យកក្បាលគ្នាទៅឯណាបាត់នោះ ហើយទុកតែដងខ្លួននៅនេះ ក៏គ្មានដែរ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** សូមអរគុណនូវការបំភ្លឺរបស់លោក ។ តែខ្ញុំនៅតែមិនច្បាស់ថា បើសិនជាគ្មានភស្តុតាង ឬ ក៏បញ្ជាក់ថា វាជាការកាត់ក្បាលយកទៅណាពិតប្រាកដ តើលោកអាចអះអាងបានទេថា ការកាត់ក្បាល ហ្នឹង អាចជាមូលហេតុនៃការយកក្បាលទៅជាបង្ហាញភស្តុតាងសម្រាប់ជំនួសនូវការធ្វើរបាយការណ៍ បានទេ?

[១១:០៩:២០]

**ឆ៖** ខ្ញុំសូមបញ្ជាក់ជូនលោកមេធាវីឡើងវិញ មានតែមនុស្សសំខាន់ទេ ដែលគេខ្លាចស-២១ ដោះលែង ហើយគេឲ្យថត ។ ដូច្នេះ មនុស្ស១៦៦នាក់នេះ មិនស្ថិតនៅក្នុងមនុស្សដែលគេសម្លាប់ ហើយ

ឲ្យថតទេ ។ ដូច្នេះ មិនមានរឿងអីដែលត្រូវយកក្បាលគេទៅបង្ហាញថ្នាក់ដឹកនាំទេ ។ នេះ គឺខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** សូមអរគុណ ។ ខ្ញុំបន្តសំណួរមួយទៀត លោកថា ព្រៃស គឺជាផ្នែកមួយនៃស-២១ ដែលទទួលបន្ទុកនៅក្នុងការអនុវត្តមាគ៌ានយោបាយ ហើយពាក់ព័ន្ធនឹងចម្លើយរបស់លោកដែលបានឆ្លើយជម្រាបអង្គសវនាការទាំងមូលថា វណ្ណៈពីរ ដែលគេទុកឲ្យ គឺកសិករ ហើយនិងកម្មករ ដែលគេទុកឲ្យរស់ ។ ចុះហេតុអ្វីបានជានៅព្រៃស ហ្នឹង មានកសិករ និងកម្មករដែរ ហើយយកទៅកម្ទេច តើអនុវត្តបែបហ្នឹងវាផ្ទុយនឹងមាគ៌ាបក្ស ឬក៏ជាចេតនារបស់អ្នកដែលធ្វើនៅព្រៃសនុ៎ង?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី ក្នុងទ្រឹស្តី គេទុកវណ្ណៈពីរ គេលើកតម្កើងវណ្ណៈពីរនេះធំណាស់ ។ ក្នុងការអនុវត្តគេលើកតម្កើងវណ្ណៈ ក៏ប៉ុន្តែ អ្នកឯងកើតមកជាកសិករមែនតែអ្នកឯងប្រព្រឹត្តក្បត់បដិវត្តន៍ អ្នកឯងជាខ្មាំង ។ ដូច្នេះ ជាបុគ្គលអ្នកឯងជាខ្មាំង តែវណ្ណៈទាំងមូល គឺវាគេគោរពអ៊ីចឹងមែន ។ នេះខ្ញុំសូមនិយាយដោយឡែកអ៊ីចឹង ។

**ស៖** អ៊ីចឹងហេតុដូច្នេះ លោកទទួលស្គាល់ថា ការធ្វើបែបនេះ គឺវាស្របទៅតាមមាគ៌ាបក្សកុម្មុយនីស្តកម្ពុជា ពិតមែនទេ?

**ឆ៖** ក្នុងរឿងអនុវត្តន៍មាគ៌ាបើសិនជាលោកចោទបញ្ហានេះ ជ្រៅណាស់ វែងណាស់ ខ្ញុំសូមនិយាយដោយខ្លីមួយម៉ាត់ ។ ការអនុវត្តជំនាន់នោះល្អៀង យើងគោរពកសិករ ក៏ប៉ុន្តែ យើងមើលការអនុវត្ត កសិករនៅឧត្តរម៉េចក៏គេសម្លាប់ចូរម្ល៉េះ ។ គេលើកតែកសិករ តាម៉ុក នេះល្អៀងហើយណាអ៊ីចឹង ហើយបានៗជាខ្ញុំគូររូបផ្គុកមួយនេះ ដើម្បីលោករំឭកនូវការអនុវត្តមិនត្រូវទិសជំនាន់នុ៎ង ។ នេះខ្ញុំសូមជម្រាបបញ្ជាក់ប៉ុណ្ណឹង ការអនុវត្តរបស់អចិន្ត្រៃយ៍តែម្តង ដែលខុស ដែលល្អៀងទៅរកកសិករមួយកន្លែង ចោលកសិករកន្លែងផ្សេងទៀត នេះជាបញ្ហាជ្រៅណាស់ ផុតពីក្របខ័ណ្ឌ ស-២១ ។

**ស៖** ដូច្នេះ បើតាមខ្ញុំយល់មានន័យថា ការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅព្រៃសហ្នឹង គឺវាមិន-- ឬក៏នៅក្នុងតំបន់ភូមិភាគឧត្តរដែលលោកលើក ដែលជាឧទាហរណ៍អំមិញហ្នឹង គឺជាការអនុវត្តដែលលម្អៀងអំពីគោលការណ៍ពិតនៅក្នុងបក្ស នៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ពិតមែនទេ?

[១១:១៣:០០]

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! អ្នកណាប្រភពដែលនាំឲ្យប្រព្រឹត្តលម្អៀងនេះ អ្នកណាជាប្រភព លម្អៀងហ្នឹងវាលម្អៀងហើយ ក៏ប៉ុន្តែអ្នកណាជាប្រភព? លេខាបក្សហ្នឹងតែម្តង ប៉ុល ពត ។ ដូច្នេះ យើងខ្ញុំអត់តបានទេ អត់តថ្លៃបានទេណាជាមួយមាគ៌ាបក្ស ។ ដូច្នេះ សូមបញ្ជាក់ជូនប៉ុណ្ណឹង ។

**ស៖** ដូច្នេះ ខ្ញុំមានសំណួរចុងក្រោយមួយទៀត សួរទៅកាន់លោក ។ លោកបានលើកឡើងអំពីការអនុវត្តដោយលម្អៀងរបស់លេខាបក្ស ប៉ុល ពត ដែលលោកចំពោះមន្ទីរព្រៃសនេះ ។ នៅក្នុងទស្សនៈ និងការយល់ឃើញរបស់លោក ញើស និងឈាម ហើយនិងសម្រែកនៃការឈឺចាប់របស់ជនរងគ្រោះ ហើយនិងរបស់សាច់ញាតិជនរងគ្រោះនៃភាពបច្ចុប្បន្នដែលកំពុងរស់នៅបច្ចុប្បន្ននេះ តើគួរតែមានការទទួលខុសត្រូវកម្រិតណារវាងអ្នកដែលអនុវត្តន៍នូវមាគ៌ាលម្អៀង ហើយនិងអ្នកដែលបន្តអនុវត្តន៍ តើវាការទទួលខុសត្រូវបែបណាដែលលោកចង់បង្ហាញ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! និយាយឲ្យចំមួយម៉ាត់ ឧក្រិដ្ឋកម្មរបស់-- ឧក្រិដ្ឋកម្មទៅលើប្រជាជនកម្ពុជាក្រោយ១៧ មេសា ១៩៨៧៥ រហូតដល់ថ្ងៃ៦ មករា ១៩៧៩ វាជាឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជាទាំងមូលទៅលើប្រជាជនកម្ពុជាទាំងមូល ក្នុងនុំងមួយលាននាក់ជាងអន្តរាយអាយុជីវិត ។ ផ្ទាល់ខ្លួនខ្ញុំ ខ្ញុំឆ្លើយទម្លាក់ទៅលើមេតែម្នាក់ទេ ខ្ញុំបានប្រកាសនៅពេលដែលចាប់ផ្តើមអង្គសវនាការយើងនេះហើយ ប៉ុល ពត ប៉ានលើកមាគ៌ានេះដោយសារមានសមាជិកបក្សរាប់ម៉ឺន ដែលចាំស្តាប់គាត់ ដែលចាំអនុវត្តទៅតាមខ្សែញាក់របស់គាត់ បានជាគាត់លើកមាគ៌ានេះ ។ ដូច្នេះ ការអន្តរាយអាយុជីវិតប្រជាជនកម្ពុជាជាងមួយលាននាក់នេះ បក្ខជនគ្រប់រូបត្រូវតែទទួលខុសត្រូវចំពោះមុខជាតិ ប្រជាជន ចំពោះមុខប្រវត្តិសាស្ត្រមនុស្សជាតិ ។ លេខាវាជាលេខាហើយ ជាអ្នកចេញមាគ៌ា តែទាំងអស់គ្នាត្រូវមានស្មារតីទទួលខុសត្រូវនេះ ដើម្បីឱនលំទោនសុំទោសជាតិប្រជាជន ដើម្បីរៀបចំសតិអារម្មណ៍សាថ្មី ឲ្យឃើញថា អានេះ វាខុស វាអន្តរាយ ។ នេះទាំងអស់គ្នាជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាពីមុនត្រូវយល់បញ្ហានេះ ។

ដោយឡែកនៅស-២១ ខ្ញុំជាអនុវត្តន៍បទឧក្រិដ្ឋនេះនៅស-២១ ខ្ញុំទទួលអត់ប្រកែកទេ ។ ឧក្រិដ្ឋកម្មទាំងអស់ បញ្ហានេះ គេជាមេ គេលើកមាគ៌ាមកខុស យើងខ្ញុំជាអ្នកអនុវត្តន៍ ខ្ញុំទទួលខុសត្រូវក្នុងការចេញមុខជំនួសបក្ស ក្នុងការអនុវត្តមាគ៌ានេះនៅក្នុងក្របខ័ណ្ឌកន្លែងមួយ ទទួលចំពោះមុខតុលាការ អ.វ.ត.ក យើងនេះ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណោះ ។

**លោក គីម ម៉េងឃី៖**

សូមអរគុណ ក្រុមបីមិនមានសំណួរអ្វីសួរទៅកាន់ជនជាប់ចោទទេ ។

**ប្រធានអង្គជំនុំ៖**

ដល់ជូនវេទិការនេះទៅមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន សូមអញ្ជើញ ។

**សួរដោយលោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទសូមគោរពលោកប្រធាន និងលោកស្រី លោកចៅក្រមព្រមទាំងអង្គជំនុំជម្រះជាទីគោរព ។ ខ្ញុំសូមសំណួរដោយត្រង់-- សួរទៅត្រង់ទៅលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច តែម្តង ដោយសារពេលវេលាខ្លីពេក ។

**ស៖** សំណួរខ្ញុំសួរថា ពីម្សិលមិញលោកបាននិយាយអំពីតំបន់ ឬមជ្ឈមណ្ឌលបាគូ លោកបានជម្រាបអង្គសវនាការ ឬលោកប្រធានថា ជាផ្នែកមួយរបស់កងពល៧០៣ ហើយលោកបានស្នើសុំដូចខាងលោកមេធាវីមុនគាត់បានសួរហើយ ។ ខ្ញុំសួរពេលវេលាដែលលោកស្នើយកមកគ្រប់គ្រងវិញនោះបាននៅខែឆ្នាំណា?

[១១:១៧:៥៨]

**ឆ៖** ខ្ញុំអាចប៉ាន់ប្រមាណឆ្នាំច្រើនណាស់ គឺពិតជាក្នុងឆ្នាំ១៩៧៨ នៅពេលដែលកងទ័ពទាំងអស់ទៅមុខ ទៅបោះទីតាំងនៅខាងមុខ ។

**ស៖** សូមអរគុណ ។ លោកបានជម្រាបលោកប្រធាន និងអង្គសវនាការពីម្សិលមិញថា មជ្ឈមណ្ឌល ឬចំណុចឈ្មោះបាគូនេះ ក្រោយមកត្រូវបានគ្រប់គ្រងដោយ ស-២៤ ឬព្រៃសនេះ អ៊ីចឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី ត្រឹមត្រូវហើយ ។

**ស៖** សូមអរគុណ ។ លោកបានជម្រាបអង្គសវនាការដែរថា លោកបានទៅព្រៃស ឬដែលលោកចៅក្រមបានសម្រេចថា យើងហៅថា ស-២៤ នេះ ខ្ញុំមិនច្បាស់ទេ សូមលោកបញ្ជាក់ថា តើលោកបានទៅព្រៃស នេះ កន្លែងមិត្ត ហ៊ុយ ស្រេ ហ្នឹងប៉ុន្មានដង?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំទៅព្រៃសបួនដង ដោយឡែក បាគូ ខ្ញុំទៅម្តងនៅពេលចាប់មិត្តហ៊ុយ ហ្នឹងឯងតែម្តង ។

**ស៖** សូមអរគុណ ។ ដោយសារលោកបានជម្រាបអង្គសវនាការ និងលោកប្រធានអំពីការបែងចែកពួកសមាសភាពចេញជាបីប្រភេទ ប្រភេទមួយ ប្រភេទពីរ ប្រភេទបី ហើយដែលប្រភេទបី នេះជាប្រភេទដែល បើសិនជានិយាយពីអ្នកទោសលោកថា វាធ្ងន់ធ្ងរជាងគេ ហើយងាយនឹងត្រូវបានយកទៅកម្ទេច ។ ខ្ញុំសូមសួរថា តើនៅ បាគូ ចែកចេញជាប៉ុន្មានប្រភេទ ឬហៅថា សមាសភាពដូចនៅព្រៃសដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី បាគូ ជាកន្លែងមួយតូចទេ មានផ្ទះ លន់ នល់ នៅពីរបីផ្ទះពីស៊ីនទឹកមួយប៉ុននុ៎ង ។ ដូច្នេះ ទុកសម្រាប់តែបុគ្គលិករបស់មន្ទីរស-២៤ នៅទេ ។ ឯចំណែក គ្នាអ្នកសមាសភាពហ្នឹង ហើយពីធ្វើការទៅកន្លែងដេករៀងខ្លួនទៅ នេះប៉ុណ្ណឹង ។

**ស៖** អរគុណ សំណួរខ្ញុំ ខ្ញុំចង់សួរថា នៅកន្លែងបាគូ ហ្នឹងមានបញ្ជូនពួកដែលលោកហៅថា សមាសភាពហ្នឹង ទៅធ្វើការនៅៗអាបរិវេណ ឬនៅក្នុងកន្លែងបាគូ ឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! មាន ទៅធ្វើក្បែរនុ៎ង ពិតជាធ្វើៗ ។

[១១:២០:៥៨]

**ស៖** សូមអរគុណ ។ សំណួរខ្ញុំសួរថា តើអ្នកដែលបញ្ជូន ចង់និយាយថា ក្រុមសមាសភាពដែលត្រូវបញ្ជូននោះ ភាគច្រើនជាស្ត្រី ឬជាកុមារ ឬជាបុរស?

**ឆ៖** នេះចូលដល់រឿងជាក់ស្តែងដែលខ្ញុំមិនដែលបានទៅឃើញ ហើយមិនដែលបានដេញសួរគេហើយ ខ្ញុំឆ្លើយអត់រួចទេ ។

**ស៖** សូមអរគុណ ។ តាមកំណត់ហេតុសាកសួរនៅលោកចៅក្រមស៊ើបអង្កេត ក៏មិនខុសគ្នាអំពីអង្គហេតុព្រមព្រៀងដែរ ជាគោលការណ៍ដែលលោកហៅថា គោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ឬដែលលោកទទួលបង្គាប់បញ្ជាបន្តទៅឲ្យខាងបុគ្គលិក ឬកម្មាភិបាល ឬយុទ្ធជន ឬយុទ្ធនារី នៅក្រោមបង្គាប់លោក ទាំងនៅស-២១ ភ្នំពេញ ទាំងនៅស-២៤ ឬព្រៃស តើការកម្រិតឲ្យអ្នកទាំងនោះគ្រប់គ្រងអ្នកទោស ឬលោកហៅថា សមាសភាពនោះ ធ្វើការមួយថ្ងៃប៉ុន្មានម៉ោង?

**ឆ៖** ជាគោលការណ៍នៅពេលដែលមិនសម្រុក យើងខ្ញុំអនុវត្តន៍ប្រាំបីម៉ោងធ្វើការក្នុងមួយថ្ងៃ នេះ ខុសពីរដូវសម្រុក ក៏ប៉ុន្តែសាមសិបថ្ងៃលើសាមសិបថ្ងៃ ។

**ស៖** អរគុណ ។ តើលោកដែលបានជ្រាប ឬបានដឹងទេថា ការប្រើមនុស្សសម្រុកធ្វើការលើសពីការបញ្ជា ឬគោលការណ៍របស់លោកមួយថ្ងៃរហូតដល់ដប់បីម៉ោងនោះ?

**ឆ៖** រដូវសម្រុកជំនាន់នោះជៀសមិនរួចទេ ត្រូវតែធ្វើ ខ្ញុំដឹង ។

**ស៖** សូមអរគុណ ។ សំណួរសួរថា អ្នកដែលលោកឲ្យឈ្មោះថាសមាសភាពនេះ ទាំងប្រភេទមួយ ប្រភេទពីរ និងប្រភេទបី ពួកទាំងអស់នោះមានធ្វើប្រវត្តិរូបជាលាយលក្ខណ៍អក្សរ បិទរូបថតក្នុងនាម ស-២១ ដែរឬទេ?

**ឆ៖** ខ្ញុំមិនច្បាស់ទេៗ រឿងនេះវាជារឿងជាក់ស្ដែង ខ្ញុំអត់បានទៅត្រួតពិនិត្យ ហើយអត់បានណែនាំដល់ល្អិតប៉ុននុ៎ងពេកទេ ។

**ស៖** អ៊ីចឹង សំណួរបន្តចង់សួរថា តើលោកធ្លាប់បានទទួលរបាយការណ៍របៀបប្រវត្តិរូប នៃពួកសមាសភាពទាំងនោះតាមរយៈមិត្តហ៊ុយ ស្រែ ឬ មិត្តហ៊ី មកដល់លោកដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំនៅតែនិយាយដដែលទេរឿងនេះ អំណាចខ្ញុំចង់ដឹងអីក៏បាន ក៏ប៉ុន្តែ ខ្ញុំអត់បានគិតគូរទេ ទុកបណ្ដោយឲ្យគេធ្វើ ។

**ស៖** សូមអរគុណ ។ សំណួរបន្តទៀត លោកធ្លាប់ និងបានជម្រាបលោកប្រធានអង្គសវនា ការអំពី ស-២១ ឬទួលស្លែងនេះ និងព្រៃស ឬស-២៤ វាកើតឡើងតាំងពីជំនាន់កងពល៧០៣ ដែលមាន ណាត កាន់កាប់ ។ មានន័យថា ក្រោយ១៧ មេសា ១៩៧៥ មកបន្តិច រហូតមកទល់នៅថ្ងៃ ៧ មករា ៧៩ ឬ ១៩៧៩ ដែលរត់ចោលទៅនោះ ។ ហើយលោកក៏បានធ្លាប់ជម្រាបអង្គសវនាការថាស-២៤ នេះជាមជ្ឈមណ្ឌលកែប្រែមិនមែនតែបុគ្គលិកចេញពីស-២១ ទួលស្លែងនេះទេ ដែលយកទៅដាក់ទីនោះ គឺមានពីអង្គភាពផ្សេងៗ ។

សំណួរខ្ញុំសួរថា តើភាពខុសគ្នារវាងបុគ្គលដែលចាត់ទុកថា ជាអ្នកទោសនៅស-២១ ទួលស្លែង និងពួកដែលរាប់ថា ជាសមាសភាពនៅស-២៤ ដែលលោកហៅថា អ្នកទោសពាក់កណ្ដាលទៅហើយនោះ អ៊ីចឹងតើកំណត់យ៉ាងម៉េច? មានន័យថាអ្នកចូលស-២១ ភ្នំពេញ លោកតែងតែនិយាយថា ទោះយូរទោះឆាប់គ្មានថ្ងៃ គ្មានឱកាសរស់ទេ កម្ទេចទាំងអស់ ។ ចុះគោលការណ៍ពួក សមាសភាពនៅស-២៤ ឬព្រៃសនេះ គោលការណ៍របស់បក្សដែលលោកបានទទួលមកនោះ ត្រៀមលក្ខណៈកម្ទេចដូចគ្នា ឬមានឱកាសលើកលែង ឬក៏បន្ធូរបន្ថយដែរ សូមពន្យល់កន្លែងហ្នឹងបន្តិច?

**ឆ៖** អ្នកណាដែលគេចាប់មកបញ្ចូលស-២១ ភ្នំពេញ ។ ស-២១ ត្រូវតែឃុំឃាំងនៅវិទ្យាល័យពញាយ៉ាត ដែលយើងខ្ញុំយកធ្វើគុកដាច់ខាត ។ ទីពីរ ត្រូវសួរចម្លើយដែលមានទារុណកម្ម ។ ទីបីសួរ

ចម្លើយចប់យកចេញ នេះជាស្វ័យប្រវត្តិ ។ ឯចំណែក អ្នកដែលរស់នៅឯខាងព្រៃសវិញ អត់ឃុំឃាំង ដូចជា អំមិញហ្នឹងសួរថា តើអ្នកឯងហៅ “អា” ហៅ “មេ” ទេ ថាអត់ទេ ។ វៃសួរចម្លើយទេ? ក្នុងដរាបណាជាទូទៅ គឺអត់មានគោលការណ៍ឱ្យវៃសួរចម្លើយពាសវាលពាសកាលអ៊ីចឹងទេ ហើយយកទៅកម្ទេចដោយគ្មានហេតុផលទេ? រង់ចាំដល់សួរចម្លើយចប់អង្កាល់យកទៅកម្ទេច? អត់ទេ ។ ដូច្នេះ ពួកដែលនៅស-២៤ ដែលហៅថា សមាសភាពនេះ ត្រូវតែខំធ្វើការ ត្រូវតែរៀនគោរពវិន័យ គេថា ឆ្វេងៗ គេថាស្តាំៗ ។ ដូច្នេះ លទ្ធភាពរស់នៅមានៗ ថ្វីត្បិតតែលទ្ធភាពស្លាប់វាមាន នៅមាននៅឡើយក៏ដោយ លទ្ធភាពរស់នៅមាន នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។ ខុសគ្នាត្រង់លទ្ធភាពរស់ វានៅមាន ឯចំណែកអ្នកចូលមកភ្នំពេញ អត់ទេណា គ្មានលទ្ធភាពរស់ទេ ត្រូវតែទៅ ។

**សះ** អរគុណ សំណួរខ្ញុំសួរបន្តថា ពាក្យថាលទ្ធភាពនៅមានរស់ជីវិត គ្រាន់តែជាការបន្តជីវិតហ្នឹង ឱ្យយូរតទៅទៀត ឬក៏គោលការណ៍ត្រូវតែកម្ទេច ឬសម្លាប់ដូចតែគ្នា?

**ឆះ** ដែលលទ្ធភាពនៅរស់នុ៎ង គឺរស់តទៅៗ ដរាបណាមានកំហុសដែលគេឃើញ គេចាប់ អាហ្នឹងបាននៅទៅៗផ្សេង បើអ្នកឯងមិនធ្វើខុសទេ នៅតែធ្វើតាមតែគេញាក់ហ្នឹង រស់ៗបាន ។

[១១:២៨:៤៧]

**សះ** សូមអរគុណ ។ មុនពេលសម្រាកនេះ លោកបានជម្រាបអង្គសវនាការអំពីសមាសភាព ហើយនៅក្នុងកំណត់អង្គហេតុឯកសាររបស់តុលាការលេខ D99 ស្តីអំពីការបញ្ជូនរឿងជម្រះ និងអង្គហេតុព្រមព្រៀងគ្នា និយាយអំពីអ្នកទោសដែលធ្លាប់បានដាក់ទណ្ឌកម្មចំពោះទង្វើខុសសីលធម៌ ឬអ្នកទោសទាំងនោះធ្វើជាឈឺ ឬយឺត ធ្វើការងារមិនពេញចិត្ត ត្រូវបានវាយដំនិងជេរប្រមាថ ។ សំណួរសួរថាតើនៅក្នុងមជ្ឈមណ្ឌលកែប្រែ ស-២៤ ពេលយប់ និងពេលថ្ងៃមានឱកាសដើរហើរដោយមិនមានការតាមដានដែរឬទេ? និយាយចំពោះអ្នកដែលហៅថា សមាសភាព ។

**ឆះ** គ្មានទេៗ ។

**សះ** អ៊ីចឹងសូមសួរបន្តថាតើពេលយប់ គេមានឱកាសចេញពីក្នុងផ្ទះ ឬក្នុងបន្ទប់ឃុំរបស់គេមកខាងក្រៅដែរឬទេ?

**ឆះ** នេះវាចូលដល់រឿងជាក់ស្តែងខ្លាំងពេក ខ្ញុំភ្លេចមិនបានទេ ក៏ប៉ុន្តែអាចចេញមកបត់ជើងតូចបត់ជើងធំបាន ។

**ស៖** សូមសួរបន្តថា ដោយសារនៅក្នុងសម័យនោះ អ៊ីចឹងខ្ញុំនិយាយអំពីស-២៤ ឬព្រៃសនេះ ហើយក៏ប្រហាក់ប្រហែលនឹងសំណួររបស់កញ្ញា ស៊ីលឃី ស្ទួតហ្សីនស្គី ដែរទាក់ទងនឹងការរៀបមង្គលការឲ្យបុគ្គលិកនៅ ស-២៤ តើដែលមានឬទេ? ស-២៤ផ្ទាល់ អត់មាននិយាយផ្សេងពីនោះទេ?

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយទេ អង្គហេតុនេះ ។ សំណួរនេះក្រៅអង្គហេតុ ។ ជនជាប់ចោទមិនបាច់ឆ្លើយទេ លោកមេធាវីប្តូរសំណួរ អាចមួយសំណួរទៀត ។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** សំណួរខ្ញុំសួរថា ការកាន់កាប់ គ្រប់គ្រងនៅព្រៃស ព្រោះខ្ញុំបាទមិនបានទទួលព័ត៌មានពីអ្នកណាមានគូ ឬមិនមានទេ ។ តើការខុសសីលធម៌ផ្លូវភេទនោះ មានន័យយ៉ាងនោះនៅស-២៤?

**ឆ៖** ស-២៤ ក៏ដូចជា ស-២១ ការខុសសីលធម៌ខាងផ្លូវភេទនេះ គឺមនុស្សពីរនាក់ ស្រីនិងប្រុសលួចដេកជាមួយគ្នា ដោយមិនបានរៀបការ ។ នេះខ្ញុំសូមជូននិយមន័យនៃបញ្ហាខុសសីលធម៌ជំនាន់នោះជូនប៉ុណ្ណេះ ។

**ស៖** ដោយសារខ្ញុំមានសំណួរតែ លោកប្រធានអនុញ្ញាតតែមួយទៀត ខ្ញុំសូមសួរសំណួរចុងក្រោយថា ជាកំហុសដែលចាត់ទុកថា មិនអាចទុកនៅស-២៤បានទៅទៀតនោះ ដែលត្រូវសម្រេចបញ្ជូនត្រង់ទៅជើងឯកក៏ដោយ ជូនមកស-២១ ភ្នំពេញក៏ដោយ វាប់បញ្ចូលទង្វើខុសអ្វីខ្លះ? សូមអរគុណ ។

**ឆ៖** ទង្វើខុសខ្ញុំបាននិយាយហើយ ពីរធំមាននិន្នាការបះបោរ ។ ឧទាហរណ៍មាននិន្នាការវៃអ្នកយាមរត់ ឬក៏រត់ នេះជាបញ្ហាខុសទីមួយធំ ។ ហើយបញ្ហាទីពីរ-- ពីរធំ ឯបញ្ហាក្រៅពីនោះ រឿងខុសសីលធម៌ ក៏ចាត់ទុកជាបញ្ហាសំខាន់ដែរ ដែលត្រូវតែគិតគូរ ។ ក៏ប៉ុន្តែ ក្នុងមួយរយៈកាលដែលខ្ញុំរស់នៅធ្វើជាប្រធានស-២១នេះ តែងផ្នែកស-២១ ក៏ដូចជាផ្នែកស-២៤ មិនមានរឿងបាតុភាពសីលធម៌បុរសនារីនេះ ដែលយើងខ្ញុំបានដឹង បានឮ ហើយបានសម្រេចលើកសំណូមពរទៅលើទេ ។ នេះ គឺសូមនិយាយប៉ុណ្ណេះ ។

[១១:៣៣:៤៥]

**ស៖** សូមអរគុណ ។ លោកប្រធាន ដោយសារមាន-- សូមតែមួយ តែបន្តិចទេ ទាក់ទងដែលគាត់ថា មានតែពីរទេ ដែលបញ្ជូនមក គឺការបះបោរ ឬក៏ការប្រឆាំងអ៊ីចឹង ។ ចុះការបញ្ជូនកុមារនោះ តើរួមប្រឆាំងដែលទេ ដែលបញ្ជូនដារីកទៅជើងឯក?

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយទេជនជាប់ចោទ អាហ្នឹងសំណួរសួររួចហើយ ទាំងសួរលើកមុននោះ ក៏ច្រំដែលដែរ ។ មិនមានកំហុសទេ ប៉ុន្តែ គោលនយោបាយ គឺខ្លាចក្រែងក្មេងសងសឹក ហើយមានគោលនយោបាយបន្ទាប់បន្សំ គឺការកាត់បន្ថយការខ្វះខ្នាយស្បៀង នេះសួររួចហើយ ។ អ៊ីចឹងអស់សំណួរហើយលោកមេធាវីក្រុមប្អូន ។

តទៅនេះ សូមប្រគល់វេទិកានេះជូនទៅមេធាវីការពារក្តី ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរដល់កូនក្តីរបស់លោក ពាក់ព័ន្ធជាមួយនឹងអង្គហេតុនៃការបង្កើត និងប្រតិបត្តិការមន្ទីរអប់រំកែប្រែសាជាថ្មី ព្រៃស ឬក៏ ស-២៤ ។ សូមអញ្ជើញលោកមេធាវី ។

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន និងសូមគោរព ។

**ស៖** លោក កាំង ហ្កេកអ៊ាវ ក្នុងចម្លើយរបស់លោកទៅនឹងសំណួររបស់លោកប្រធានពីម្សិលមិញ លោកបាននិយាយថា នៅស-២៤ ក៏ដូចជានៅស-២១ ដែរ សិទ្ធិក្នុងការដើរហើរ គឺមានកម្រិត ។ គោលការណ៍នេះ ត្រូវបានអនុវត្តន៍ទៅលើអ្នកទោស ហើយលោកក៏បាននិយាយថា វាក៏អនុវត្តន៍ទៅលើបុគ្គលិកមន្ទីរស-២៤ និងស-២១ដែរ ហើយក៏ទៅលើរូបលោកផងដែរ តើមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! គឺពិតជាមែន ខ្ញុំគ្រាន់តែសុំអធិប្បាយបន្ថែមមួយម៉ាត់ថា ការដើរហើរ ត្រូវដើរហើរក្នុងភារកិច្ចចាត់តាំង ។ ផ្ទាល់ខ្លួនខ្ញុំទៅព្រៃស គឺដើរហើរក្នុងភារកិច្ចចាត់តាំង។ ទៅធ្វើការជាមួយនឹងមេ គឺដើរហើរក្នុងភារកិច្ចចាត់តាំង ។ ដូច្នេះ ទូទាំងប្រទេសត្រូវគោរពបញ្ហានេះ ។ ឯចំណែក ឧទាហរណ៍ខ្ញុំលើកមួយទៀត កម្មាភិបាលសួរចម្លើយ អត់ដែលបានដើរចេញទៅឯណាទេ ភារកិច្ចចាត់តាំងគ្មានដើរ ។ ដូច្នេះ វាអ៊ីចឹង ក្នុងបញ្ហាសិទ្ធិសេរីភាពក្នុងការដើរហើរ គឺដើរហើរក្នុងភារកិច្ចចាត់តាំង ។ សូមបញ្ជាក់ជូនដោយស្មោះប៉ុណ្ណោះ ។

[១១:៣៦:៤៤]

**ស៖** សូមអរគុណ ។ ហើយពីម្សិលមិញផងដែរ លោកក៏បានលើកថា លោកមិនដែលបានទៅស្រុកកំណើត មិនដែលបានទៅសួរឪពុកម្តាយអីទេ គឺថាបានតែម្តងក្រោយរៀបការរួច ។ អ៊ីចឹងជាក់ស្តែងលោកអាចពន្យល់បានដែលទេថា តើសិទ្ធិដើរហើររបស់លោកត្រូវបានកម្រិតយ៉ាងដូចម្តេច?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំបានបញ្ជាក់អំមិញហើយ ដើរហើរតាមចាត់តាំង ដើម្បី

បំពេញភារកិច្ច ។ នេះជាបញ្ហាចាំបាច់ ក៏ប៉ុន្តែពេលខ្លះក៏អនុគ្រោះដែរ ។ ឧទាហរណ៍ខ្ញុំការរួចហើយ អនុញ្ញាតឲ្យខ្ញុំទៅលង្វែក ជូនប្រពន្ធទៅនៅថ្ងៃ៣១ ធ្នូ ។ ដល់ស្អែកឡើងថ្ងៃ១មករា ១៩៧៦ ខ្ញុំជូនម្តាយខ្ញុំទៅស្មោង នេះបក្សអនុគ្រោះ ។ ហើយទន្ទឹមនេះ ប៉ុន្មានថ្ងៃមុនក៏ខ្ញុំឮ ខ្ញុំអាចនិយាយបានថា អង្គប្រជុំឮតែពីខ្ញុំនិយាយទៅ ពីខ្ញុំទៅលេងបង ហុក ទៅរកហ្វូបអីៗ នៅនឹងផ្ទះគាត់នុ៎ង ក៏ខ្ញុំបានសុំច្បាប់មេ ។ ដូច្នេះការដើរហើរក្នុងករណីក្រៅក្របខ័ណ្ឌចាត់តាំង មានពេលខ្លះបក្សអនុគ្រោះ ដូចជាខ្ញុំទៅស្រុក ហើយនិងទៅហូបអីផ្ទះបងហុក ម្តងពីរម្តង មួយជីវិតខ្ញុំមែន ។

**ស៖** សូមអរគុណនិងសួរទៅទៀត ។ ពីម្សិលមិញ លោកបានជូនជាឧទាហរណ៍អំពីករណីបុគ្គលិករបស់ នុន ហ៊ុយ ដែលរត់គេចខ្លួន ។ តើស្រួលរត់គេចខ្លួនដែរទេកាលនៅក្នុងសម័យនោះ? ពីព្រោះថាបុគ្គលិករបស់គាត់ កាន់តែអួរបស់គាត់ហ្នឹងរត់ទៅ ដូចអត់មានឃើញអ្នកណាតាមចាប់អីទៅដោយស្រួល ។ អ៊ីចឹងសូមលោកបញ្ជាក់ ។

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! និយាយពីរត់នេះ ត្រូវពិនិត្យលទ្ធភាពពីរ ត្រូវពិនិត្យបញ្ហាពីរ ពិនិត្យទិដ្ឋភាពពីរ ។ ទិដ្ឋភាពទីមួយ គឺយើងចេញពីកន្លែងធ្វើការ ផ្លាស់ប្តូរទីកន្លែងទៅកន្លែងមួយទៀត ។ ចេញបាន ក៏ប៉ុន្តែ យើងទៅស្នាក់នៅឯណា ហ្នឹងដែលជាបញ្ហា អត់អ្នកណាដោះស្រាយរួចទេ ។ អង្កាល់សង្គមកម្ពុជាប្រជាធិបតេយ្យជំនាន់នោះ អ្នកដែលចេញពីអង្គភាពមាន ទៅដល់វាអត់បាយស៊ីវាទៅជ្រកនឹងព្រៃក្បែរៗនុ៎ង ដល់យប់ឡើងចូលមកលួចបាយស៊ីទៅវិញ ។ ហ្នឹងហើយដែលជំនាន់នោះ គេហៅថា ចោរព្រៃ ហ្នឹងហើយដែលគេហៅថា ចោរព្រៃ ។

ដូច្នេះ បើយើងគិតថា ដើរចេញពីអង្គភាពទៅ វាចេះតែទៅបានហើយ ក៏ប៉ុន្តែសួរថា ទៅជ្រកនៅឯណា បញ្ហានេះជាបញ្ហាដែលអត់មានអ្នកណាហ៊ានរត់ គឺគិតដល់បញ្ហាជ្រកនៅឯណាហ្នឹងឯងជាធំ ។ នេះនិយាយមួយម៉ាត់ គិតដល់បញ្ហានុ៎ង មិនមានអ្នកណារត់រួចទេ ។ ខ្ញុំសូមជូនឧទាហរណ៍មួយទៀត នៅថ្ងៃ២៩ តុលា ឆ្នាំ១៩៦៧ ខ្ញុំរត់ចេញពីស្គន់ ឈប់ធ្វើសាស្ត្រាចារ្យទៅធ្វើបដិវត្តន៍ជាមួយនឹងខ្មែរក្រហម ។ មានអ្នកណាផ្លូវ ចាប់តាំងពីភ្នំពេញទៅ ដឹងកន្លែងជ្រកនៅ ដឹងអីទាំងអស់ ។ ដូច្នេះ រត់រួចមានខ្សែ មានការចាត់តាំង មានកន្លែងជ្រក នេះគឺសូមបញ្ជាក់អ៊ីចឹង ។ សរុបមកវិញ អ្នកដែលមានខ្សែចាត់តាំង មានការជ្រកហ្នឹងក៏ដោយ ឲ្យតែដាច់ខ្សែចាត់តាំង គឺគេចាប់ហើយ ។ ខ្ញុំផ្ទាល់ខ្លួននោះ ទិសរបស់បក្សបញ្ជូនរត់ បញ្ជូនទៅព្រៃសាន ក៏ប៉ុន្តែ ដាច់ខ្សែនៅត្រង់ក្រចេះ ខ្ញុំមកត្រេងត្រាំងៗនៅហ្នឹងចំការលើ

គេទៅចាប់យកមក នេះជាក់ស្តែង ។ ហើយជំនាន់ឆ្នាំ១៩៧៥ មានលេខាវរសេនាតូចម្នាក់ លេខាវរសេនាតូចកងពិសេសផង ឈ្មោះ ស៊ុយ ផល វត់ មិនដឹងដាច់ខ្សែចាត់តាំងទៅណាទេ មកពួននៅក្បែរពេទ្យចិន គេចាប់មកទៀត ។ ដូច្នេះ យើងត្រូវគិតមើលបញ្ហានេះ នេះទីមួយ ។

មួយទៀតផ្ទាល់ខ្លួនខ្ញុំ មេតាមដានប្រចាំថ្ងៃ វត់មិនរួចទេ បាត់ខ្ញុំមួយថ្ងៃ តែប៉ះមេទូរស័ព្ទមករកមិនឃើញ ទូរស័ព្ទខ្វាត់ខ្វែងពេញផែនដីឲ្យស្កាត់ទប់ខ្ញុំ ។ ដូច្នេះ ទៅមិនរួចទេ វន វេត ក៏ចេញមិនរួចក៏ដោយសាររឿងហ្នឹង ខ្ញុំក៏ចេញមិនរួច ។ នេះបើសិនជាចង់វត់ ។ នេះខ្ញុំសូមនិយាយប៉ុណ្ណឹង ។

[១១:៤១:៣៧]

**ស៖** សូមអរគុណ ។ ពីម្សិលដដែល លោកតបនឹងសំណួររបស់លោកចៅក្រម ធូ មណី លោកបាននិយាយថា “ពាក្យអប់រំកែប្រែ មានន័យថា អប់រំកែប្រែខ្លួន កសាងខ្លួនជាថ្មី ធ្វើឲ្យខ្លួនក្លាយជាមនុស្សថ្មី” តើពាក្យថាធ្វើឲ្យខ្លួនក្លាយជាមនុស្សថ្មីហ្នឹង វាមានន័យយ៉ាងម៉េច? ហើយខ្លួនលោកៗមិនបាច់អប់រំទទួលការអប់រំទៀតទេ ព្រោះលោកហ្នឹងត្រូវបានអប់រំល្អហើយ លោកខ្លួនលោកសម័យហ្នឹងស-២១ហ្នឹង លោកជាមនុស្សថ្មីរួចហើយ តើលោកអាចពិពណ៌នាពីវិធីក្នុងការធ្វើខ្លួនឲ្យក្លាយខ្លួនជាមនុស្សថ្មីបានទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំមានចេតនានឹងធ្វើខ្លួនពីមនុស្សធម្មតាឲ្យទៅជាជនកុម្មុយនីស្ត ។ នេះពីអង្កាល់ឆ្នាំ១៩៦៤ ឆ្លងកាត់តាមការរៀនសូត្រ ឆ្លងកាត់តាមការលត់ដំផ្សេងៗ បក្សក៏បានទទួលស្គាល់ខ្ញុំថា អាចចូលបក្សបាន ។ នេះវាក្លាយខ្លួនទៅជាបក្ខជនរបស់បក្សកុម្មុយនីស្តកម្ពុជាហើយ វាទៅជាមនុស្សថ្មីមួយដែល ឌុច ពេលនុ៎ង វាខុសពី កាំង ហ្កេកអ៊ាវ សាស្ត្រាចារ្យគណិតសាស្ត្រនៅវិទ្យាល័យស្គន់ ។

[១១:៤៣:១៨]

**ស៖** សូមអរគុណ ។ អ៊ីចឹងកាលលោកជាសាស្ត្រាចារ្យ លោកជាមនុស្សចាស់ក្នុងសង្គមចាស់ អ៊ីចឹង ឌុច ជាប្រធានស-២១ លោកជាមនុស្សថ្មីក្នុងសង្គម ក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ ហើយដល់ ឌុច បច្ចុប្បន្ននេះ ក្នុងរបបបច្ចុប្បន្នយើងសព្វថ្ងៃនេះ តើលោកទទួលខុសត្រូវចំពោះអាយុក្មេងៗ១៦០នាក់យ៉ាងម៉េចខ្លះដែរ ដែលគេបញ្ជូនត្រង់ពីស-២៤ ទៅជើងឯក តើលោកទទួលខុសត្រូវយ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំបានរាយការណ៍ជូនអង្គប្រជុំហួរហែមកហើយ រឿងអីក៏ដោយ ជាពិសេសការវិវឌ្ឍសតិអារម្មណ៍របស់មនុស្ស វាមិនលោតផ្លោះ គឺវាទៅសន្សឹមៗ ។ ការចាប់អារម្មណ៍របស់ខ្ញុំអំពីឧក្រិដ្ឋកម្មក៏វាទៅសន្សឹមៗ តាំងពី១៩៧៣ ខ្ញុំបាននិយាយហើយ ខ្ញុំមានការតក់ស្លុត

ចំពោះអាយុជីវិតមនុស្សតាំងពី[១៩]៧៣មក ហើយខ្ញុំមានការវិវឌ្ឍតមកទៀត ចេះតែចង់សុំចេញ ។ នេះមិនមែនជារឿងធ្វើពុត ឬក៏កាច់រាងធ្វើឯងអ្នកឈឺចាប់ស្អីនោះទេ ។ រឿងវាវិវឌ្ឍន៍ទៅអ៊ីចឹងមែន ។ ហើយដល់ចុងក្រោយបំផុត ខ្ញុំនិយាយលោតផ្លោះទៅចុះ ព្រោះរឿងហ្នឹងខ្ញុំនិយាយច្រើនដងហើយ ខ្ញុំសុខចិត្តទទួលខុសត្រូវចំពោះវិញ្ញាណក្ខន្ធមនុស្សដែលស្លាប់ទៅ ដោយប្រើវិធីខាងផ្លូវចិត្ត សែនជាសម្ងាត់ ។ នេះជាបញ្ហាមួយ ។ ដល់យើងមកជួបគ្នានៅអយ្យការយោធា លោកមេធាវីជ្រាបហើយ តាមផ្លូវច្បាប់ គឺយើងឆ្លើយទម្លាក់កំហុសទៅលើគេ ទៅលើរដ្ឋាភិបាល តាំងខ្លួនខ្ញុំថាជាប៉ូលិស ថាមិនមែនជាជនឧក្រិដ្ឋអីទេ ប៉ូលិស វាត្រូវតែគោរពរដ្ឋាភិបាលអ៊ីចឹងហើយ ។ ក៏ប៉ុន្តែ ដល់យើងមកជួបគ្នានៅ អ.វ.ត.ក នេះទាំងបីនាក់ ។ ឥឡូវនេះ យើងឆ្លងកាត់ការសួរក្នុងរយៈកាលស៊ើបអង្កេតមកដល់ការឆ្លងនៅក្នុងអង្គសវនាការនេះ ជាតិប្រជាជនកម្ពុជា លោកឃើញខ្ញុំយ៉ាងម៉េច ជាមនុស្សមួយថ្មីទៀតហើយឬនៅ? ខ្ញុំដាក់ខ្លួនជូនជាតិប្រជាជនកម្ពុជា លោកវិនិច្ឆ័យខ្ញុំចុះ ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** សូមអរគុណ ។ ឥឡូវខ្ញុំសួរតទៅទៀត ។ មុននឹងយកពួកសមាសភាពណាម្នាក់ទៅកម្ទេចតើសម្រេចត្រឹមលោក ឬក៏មានការសម្រេចពីថ្នាក់លើលោក? សូមលោកបញ្ជាក់?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! រឿងនេះជារឿង ខ្ញុំបញ្ជាក់សាថ្មីជូនអង្គសវនាការ ពួកសមាសភាពដែលអប់រំនៅសាថ្មី--នៅស-២៤ ហើយតាមការវិភាគ និងសន្និដ្ឋានរបស់ខ្ញុំ ក៏ប្រហែលជាសម្រាប់ទូទាំងប្រទេសដែរ ។ គោលការណ៍គឺបក្សប្រគល់ឲ្យគណៈកម្មាធិការមន្ទីរអប់រំហ្នឹងគេសម្រេចរួចទៅហើយ ។ សម្រេចទាំងអប់រំ សម្រេចទាំងការពារមិនឲ្យរត់ សម្រេចទាំងការពារមិនឲ្យតដៃបានប្រតិកម្មបះបោរបាន ។ នេះគឺគេប្រគល់អ៊ីចឹង ។ ដូច្នេះ ក្នុងករណីជាទូទៅ ដូចខ្ញុំបានរាយការណ៍ជូនលោកព្រះរាជអាជ្ញា ស្នឹត រួចហើយ ខ្ញុំរវល់ប្រគល់ផ្ទេរសិទ្ធិអំណាចនេះទៅឲ្យអនុលេខា និងសមាជិកគេធ្វើ ។ និយាយដូច្នេះ ខ្ញុំលោកស្នឹតក៏ជ្រាប អង្គសវនាការទាំងមូលក៏ជ្រាបមិនមែនខ្ញុំគេចឧក្រិដ្ឋកម្មទេ ប៉ុន្តែការងារវាច្រើនពេក ខ្ញុំប្រគល់ការងារទៅឲ្យគេពីព្រោះគេក៏ធ្លាប់ធ្វើរួចមកហើយ ។ ដូច្នេះ និយាយមួយម៉ាត់មក ឆ្លើយឲ្យចំសំណួរលោកមេធាវីគឺ គ្រប់ករណីទាំងអស់គេសម្រេច ហើយគេប្រាប់ខ្ញុំជាក្រោយ ។ នេះសូមនិយាយជាទូទៅក្នុងលក្ខណៈទូទៅ ។

**ស៖** សូមអរគុណ ។ ឥឡូវខ្ញុំសួរក្នុងឯកសារ ។ អំពីពាក្យថា ដោះលែង ដំបូងខ្ញុំសុំសួរលោកថា

តើលោកមើលឃើញថា ឯកសារលេខD15914.10 និងឯកសារ E47.10 ជាឯកសារតែមួយដូចខ្ញុំយល់ដែរមែនឬទេ? តើលោកយល់ដូចខ្ញុំមែនឬទេ?

[១១:៤៩:២៥]

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ឯកសារទាំងពីរនេះជាឯកសារដូចគ្នាតែមានលេខកូដពីរខុសគ្នា ជាឯកសារតែមួយទេ ។

**ស៖** បន្ទាប់មកទៀតសូមលោកបញ្ជាក់ថា លោកនៅតែរក្សាគោលជំហរថា E47.10 ជាបញ្ជីកម្មេចមែនឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី ឯកសារ E47.10 ពិតជាបញ្ជីកម្ទេច ។

**ស៖** បើកម្ទេចពិតមែន ហេតុដូចម្ដេចបានជា ហ៊ី សរសេរថា ដោះលែង? សូមលោកបញ្ជាក់?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ពាក្យដោះលែងនេះ ខ្ញុំវិភាគនិងសន្និដ្ឋានទៅ វាជាស្រមោលនៃល្បិចកលដែល ណាត បង្រៀនហ៊ី ហើយវានៅជាប់ក្នុងក្បាលគ្នាហ្នឹង ។ ប្រហែលជាអាច ណាត បង្រៀនថា យើងអាចសរសេរជាយុទ្ធវិធីមួយនៅលើក្រដាសថាដោះលែង ក៏ប៉ុន្តែតាមពិតយើងកម្ទេច ។ នេះជាយុទ្ធវិធីរបស់បក្ស ។ អ៊ីចឹងហើយបានជាពេលនេះគ្នាក៏ខំសរសេរពាក្យដោះលែងមកឲ្យខ្ញុំនៅក្នុងករណីដែលកម្ទេច យុទ្ធជន និងកម្មាភិបាលមួយរយនាក់នេះ ។ ដូច្នេះ វាជាអារម្មណ៍មួយដែលនៅជាប់នឹងគ្នា ។ ម៉េចក៏បានខ្ញុំវិភាគយ៉ាងនេះ? ឯកសារលេខ D57 Index 003 ជាឧទាហរណ៍ស្រាប់ ។ ឯកសារ នេះមានចំណងជើងថា “ឯកសាររបស់វរសេនាតូចលេខ៩៦ អនុសេនាធំ លេខ៤៤ របស់កងពល ៧០៣” ក៏ពិតមែន ។ វាមានចំណងជើងថា “ឯកសារដោះលែង” ។ ក៏ប៉ុន្តែ ថាបញ្ជាដែលឯកសារនេះវាមក នៅឯ ស-២១ ឯណេះ បានជាខ្ញុំប៊ានថាឯកសារនេះវាមកនៅ ស-២១ ព្រោះអក្សរ TSL ហ្នឹង វាជាឧទាហរណ៍ស្រាប់ វាជាភស្តុតាងស្រាប់ ។ ដូច្នេះ កាលដែលឯកសារនេះវាមកនៅស-២១ នេះ វាបញ្ជាក់ថា ណាត ពិតជាប្រើ ហ៊ី ឲ្យទៅដឹកនាំ មិត្តហ៊ិន លេខាវរសេនាតូច៩៦នេះ កម្ទេចមនុស្សហើយសរសេរឯកសារថាដោះលែង ។ មនុស្ស៤៩នាក់នេះ អត់ដោះលែងទេ ។ នេះភស្តុតាងទីមួយហើយ ហ៊ី ខ្លួនឯងនេះជឿតាម ណាត រហូតដល់ឯកសារ E5/2.8 មិត្តហ៊ី ខ្លួនឯងសរសេរ ដោះលែងនៅថ្ងៃទី៨ ខែ០៣ ឆ្នាំ១៩៧៦ ។ ដូច្នេះ អារម្មណ៍ហ្នឹងវាជាប់ បានជាមិត្ត ហ៊ី សរសេរអាពាក្យដោះលែងនេះ ។ វាជាប់តាមជំនឿលើ ណាត ថាអាហ្នឹងជាយុទ្ធវិធីដែលបក្សអនុវត្ត។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។

[១១:៥៣:០៤]

**ស៖** សូមអរគុណ ។ អ៊ីចឹងសូមលោកពន្យល់អំពីពាក្យរត់ ពាក្យថា “រត់” នៅក្នុងឯកសារ E47.21, E47.22, E47.23 តើវាយ៉ាងម៉េច? សូមលោកពន្យល់ឲ្យបានច្បាស់?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ក្នុងមួយជីវិតខ្ញុំដែលដឹកនាំកិច្ចការនៅស-២១ នេះ ខ្ញុំមិនដែលឮពាក្យថា រត់រួចក្រៅពីមិត្តម្នាក់អ្នកកាន់តេអូរបស់ មិត្តហ៊ុយ ទេ ។ ជាពិសេសទៅទៀត កម្មាភិបាលអនុសេនាធំឈ្មោះ ស៊ឹម មែល ហៅ ម៉ាន នៅក្នុងឯកសារ E47.23 ត្រង់លេខរៀង ១០២ ។ មិត្ត ស៊ឹម មែល ហៅ ម៉ាន នេះខ្ញុំស្គាល់ ស្គាល់ច្បាស់ណាស់ ។ គាត់មានចំណុចខ្សោយពីរជាសំខាន់ ។ ចំណុចខ្សោយទីមួយ ធ្វើការងារអត់ដិតដល់ទេ មុខមាត់ ធ្វើការងារអីក៏ដោយច្បោលៗ ឲ្យធ្វើអីក៏ធ្វើមិនកើត ។ ប៉ុន្តែ ចំណុចខ្សោយមួយទៀត គឺគាត់គោរពតែ ណាត ទេ អ្នកណាក៏គាត់មិនស្ដាប់ដែរ ។ ជាមួយនឹងខ្ញុំគាត់គ្រាន់តែមិនប៉ិាន ។

ដូច្នេះ ប្រើជាកងការពារក៏ប្រើមិនបាន គេមិនទទួល ប្រើឲ្យសួរចម្លើយក៏ប្រើមិនកើត ។ ដូច្នេះខ្ញុំនិងមិត្តហ៊ី សម្រេចឲ្យគាត់ទៅស្រែទៅជួយការងារ មិត្តហ៊ុយ ។ បាតុភាពចេះតែរាយការណ៍មកបន្តបន្ទាប់ រហូតដល់ខ្ញុំសុំអនុញ្ញាតពីខាងលើចាប់មិត្ត ណាត ។ ដូច្នេះ តាមខ្ញុំចាំមិត្ត ណាត នេះវាមានបាតុភាពទៅផ្សេងទេ ក៏ប៉ុន្តែក្នុងឯកសារនេះគឺឯកសារលេខ47.23 នេះ ត្រង់ លេខរៀង ១០២ ដាក់ថា ស៊ឹម មែល ហៅម៉ាន អាយុ២៤ ឆ្នាំ ប្រុស មន្ទីរស-២១ ប្រធានអនុសេនាធំ ផ្នែកកសិកម្ម មន្ទីរ២៤ រត់នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៧៧ ។ ចាប់បាននៅថ្ងៃ ២៧ តុលា ១៩៧៧ ។ មូលដ្ឋានចាប់បាន ។ នេះវាមាននៅក្នុងឯកសារអ៊ីចឹង ។ ក៏ប៉ុន្តែ បើតាមខ្ញុំចាំមិនមានបញ្ហានេះទេ ។

ដោយសារយកបញ្ហានេះជាគោល ខ្ញុំគិតថា ឯកសាររដ្ឋដែលមាននៅក្នុងប៉ុន្មានឯកសារនេះ វាជាឧបាយកលដែលហ៊ុយ ជឿតាមរបៀប ណាត ទៀតហើយ ។ គេត្រូវប្រឈមមុខធ្ងន់ធ្ងរដែរ ចំពោះភារកិច្ចដែលបក្សប្រគល់ឲ្យគេ ដែលខ្ញុំជាតំណាងបក្សសង្កត់ទៅលើគេ ។ មនុស្សរត់មិនបាន មនុស្សបះបោរមិនបាន អ្នកឯងទទួលខុសត្រូវចំពោះមុខបក្ស ។ រួចខ្ញុំអត់បានទៅតាមដានគេ ណែនាំគេលើកទឹកចិត្តគេ ឲ្យធ្វើការងារបែបនេះ បែបនោះទេ ។ ម្ល៉ោះហើយដើម្បីរក្សាខ្លួនគេកុំឲ្យវាជាប់ចោទប្រកាន់របស់បក្ស គេចេះតែរកវិធីហើយ ។ ដូច្នេះ ខ្ញុំជឿថា ពាក្យ “រត់” រត់រួចក៏ដោយ រត់មិនរួចក៏ដោយ គឺគេចាប់ហើយៗ ។ នេះខ្ញុំសូមសន្និដ្ឋានជាជំហានដំបូងពាក្យ“រត់” ដែលនៅក្នុងឯកសារទាំងបីនេះ E47.21, E47.22 ប៉ុណ្ណេះ។ ។ ឯចំណែក E47.23 វាជាការពន្យល់ ។ វាជាការពន្យល់នៅក្នុងសេចក្ដីសរុបនៃ E47.22 ។ យើងមើល E47.22 ត្រង់ កូឡោនវាមួយ កូឡោនទីមួយកង កូឡោនទីពីរដក កូឡោនទីបី

ប៉ូលិស កូឡោនទីបួន រត់ ។ យើងមើលនៅក្នុងកូឡោនទីបួន នៅក្នុងបញ្ជE47.22 នេះយើងឃើញ “រត់” ១០២នាក់។ ដល់មក យើងមើលឯកសារលេខ E47.23 នេះ១០២ត្រឹម ត្រឹម ស៊ឹម មែល ហៅ ម៉ាន ។ ដូច្នេះ សរុបមកឯកសារទាំងអស់នេះ មានឈ្មោះថារត់ក៏ប៉ុន្តែខ្ញុំមិនជឿទេ ព្រោះខ្ញុំវាអត់ដែលបានទទួលព័ត៌មានណាពីរឿងរត់ហ្នឹងសោះ។ ប្រសិនបើនិយាយអំពីរឿងរត់មែន សួរថារត់រួចទេ រត់ដល់ទៅរាប់រយនាក់? ច្បាស់ជាមូលដ្ឋានគេចាប់បានខាន មិនខាន ហើយដល់ទៅមូលដ្ឋានគេចាប់បានល្បីដល់ខាងលើហើយ ។ ម៉េចៗ មិត្តឌុច ពួកនោះរត់ណា មិត្តមិនដឹងទេ? ដូច្នេះអត់ទេ រឿងរត់ក៏ដោយ តែបែកការណ៍ដល់មូលដ្ឋានគេចាប់ ។ ហើយតែដល់ចាប់ហើយគេសួរមករកកំណើតដើមហើយ រត់ពីណា កងណា ។ ដូច្នេះខ្ញុំមិនជឿសោះថាមនុស្ស១០២នាក់នេះរត់ ។ ខ្ញុំជឿថា ជាយុទ្ធវិធីរបស់គេដើម្បីដោះស្រាយមនុស្សនោះយកទៅកម្ទេច ហើយគេសរសេរថារក្នុងឯកសាររបៀបដូចមិត្ត ហ៊ី គាត់ចារទៅ ណាត បង្គាប់នោះខ្ញុំគិតអ៊ីចឹង ។

នេះខ្ញុំ សរុបមកពាក្យរត់មួយម៉ាត់ គឺរត់មិនរួចទេ ។ ឯកសារដែលមានទាំងប៉ុន្មាន E47.21, E47.22 នេះ គឺខ្ញុំនៅ តែអះអាងថាពាក្យរត់ រត់មិនរួច ។ ដោយឡែក ខ្ញុំសូមអធិប្បាយតទៅទៀតអំពី E47.21 ។ E47.21 គាត់មានសរសេរ TSL4.513 មានអក្សរ មិត្តហ៊ុយ នៅនេះច្បាស់ថែស បាត់ដប់នាក់ បាត់ម្នាក់ បាត់ពីរនាក់អីទាំងអស់ ។ ហើយដល់គាត់សរសេរលម្អិត គាត់មានសរសេរទេ អាហ្នឹងធ្វើនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៧៨ មន្ទីរ-២១, ហ៊ុយ ។ នេះមានហត្ថលេខាអី មានអីគាត់ច្បាស់លាស់។ ដូច្នេះ វាពិតជាឯកសាររបស់មន្ទីរស-២១ ហើយ មន្ទីរស-២៤ ដែលមិត្តហ៊ុយ កាន់កាប់ហ្នឹងហើយជូនមក ស-២១ មកដល់ភ្នំពេញហើយ បានៗជាមេចំណារ TSL ជាភស្តុតាង ទុកបញ្ជាក់ ។ នេះ E21 ខ្ញុំសូមអធិប្បាយប៉ុណ្ណេះ ។ ហើយក្នុង E21 នេះ គាត់ថារត់៣២នាក់ ចាប់បានវិញ១៦នាក់បាត់រហូត ១៦នាក់ ។ បើបាត់រហូតដល់ទៅ១៦នាក់ អាចកំបាំងនៅភូមិដ្ឋាន គឺគេចាប់ហើយ ។ ហើយតែគេចាប់ហើយល្បីដល់ខាងលើហើយ ។

ដូច្នេះ សរុបមកវិញឯកសារE47.21 នេះក៏នៅតែជាយុទ្ធវិធី ដើម្បីចារទុកក្នុងឯកសារនេះ ហើយតាមពិតគេដោះស្រាយបញ្ចេញអ្នកណាដែលមានលទ្ធភាពអាចរត់ ឬក៏អាចតដៃអី គេយកចេញបាត់ហើយ ដោយមិនសុំយោបល់ខ្ញុំ ហើយគេចារទុកឯកសារដើម្បីការពារខ្លួនគេ ។

ហើយសូមតទៅទៀត ឯកសារលេខ E4722ៗ ក៏មានអក្សរ TSL ដែរ TSL 4.527 ចំណងជើងស្ថិតិកម្លាំងបាត់មុខ ។ មិត្តហ៊ុយ គាត់សរសេរប្រចាំឆ្នាំ១៩៧៧ កឡោនទីមួយ កង កង១១ កង១២

កង១៣ អី ។ ឯចំណែក កូឡោនទីពីរ គេនិយាយ ដក ដកបូកសរុបទៅ វា២៣៥០នាក់ ។ កូឡោនទីបី ពលី មានន័យថាស្លាប់ អស់២២៧នាក់ កូឡោនទីបី រត់១០២នាក់ ។ ដូច្នេះ អា ១០២នាក់ក្នុងកូឡោនទីបី នេះ គឺពិតជាដកស្រង់ចេញពីឯកសារលេខ E4723 ហើយព្រោះគេនិយាយលម្អិតនៅក្នុងនុ៎ង ។

ចំណុចនេះ ខ្ញុំទទួលស្គាល់ថាជាឯកសាររបស់មន្ទីរ ស-២៤ បញ្ជូនមកដល់ស-២១ ហើយ ភស្តុតាង TSL ជាឧទាហរណ៍ស្រាប់ ។ ត្រង់កូឡោនទីបី វាមានបញ្ជាក់ហើយថា ១០២នាក់ រត់នេះ ខ្ញុំបានបញ្ជាក់មិញហើយថា វាឈរលើឯកសារE47.23 ។ ក៏ប៉ុន្តែ ខ្ញុំសូមជូនជាការចាប់អារម្មណ៍អំពីចំនួនដក១ដាក់ថា ២៣៥០ ។ បើប្រៀបធៀបចំនួនដកនេះទៅនឹងសេចក្ដីរាយការណ៍ដែល មិត្តហ៊ុយសរសេរបន្ថែមថាប្រចាំ១៩៧៧ ។ ដកប្រចាំឆ្នាំ១៩៧៧ វា២៣៥០នាក់ ធ្វើឲ្យខ្ញុំមានការភ្ញាក់ផ្អើរច្រើនដែរ ។ និយាយយ៉ាងនេះ ខ្ញុំអត់បដិសេធថា តម្លៃថាឧក្រិដ្ឋកម្មខ្ញុំប៉ុណ្ណេះប៉ុណ្ណោះទេ ក៏ប៉ុន្តែខ្ញុំសូមវិភាគថា បើតាមការដែលខ្ញុំធ្លាប់ក្ដាប់នោះហើយដឹងព័ត៌មានជារួមៗមក ដកក្នុងមួយឆ្នាំរហូតដល់ ២៣៥០នាក់ មិនមែនទេ ។ ខ្ញុំគិតថា នេះជាស្ថិតិដែលគិតចាប់តាំងពីកកើតស-២៤ មក ។ ហើយ ពលី ២២៧នាក់ ក៏មិនមែនប៉ុននុ៎ងដែរ ។ បើសិនជា ប៉ុននុ៎ងមែនក៏គប្បីរាយការណ៍ឲ្យខ្ញុំដឹង ។

ដូច្នេះ ចំនួនពីរនេះ ខ្ញុំគិតថា ដើម្បីច្បាស់លាស់អាចមានឯកសារថែមទៀតនៅព្រៃស ដែលនៅសល់ ពីព្រោះយើងឃើញហើយឯកសារព្រៃស ដែលនៅសល់ នេះឯកសារ443 នេះ វាឯកសារដែលនៅពីព្រៃសនោះទេ អត់ផ្ញើមកដល់ ស-២១ ភ្នំពេញទេ ។ ដូច្នេះ ឈរលើឯកសារហ្នឹង ដើម្បីមើល១ ។ តើអាហ្នឹងវាចាប់ផ្ដើមតាំងពីកកើតស-២៤ មក ឬយ៉ាងម៉េច? បើវាចាប់ផ្ដើមពីកកើត ស-២៤ យើងបញ្ចូលទៅក្នុងបញ្ជីរួមឧក្រិដ្ឋកម្មទៅលើជីវិតមនុស្សប៉ុណ្ណោះ ។ ហើយបើសិនជា ឯកសារវាបញ្ជាក់ថាវាត្រឹមតែឆ្នាំ១៩៧៧ យើងគួរគប្បីនាំគ្នាស្រាវជ្រាវតទៅទៀតឲ្យឃើញ តើមុននោះអស់មនុស្សប៉ុន្មាននាក់? នេះខ្ញុំសូមលើកជាបញ្ហាហ្នឹង ដើម្បីយើងទាំងអស់គ្នារកឲ្យឃើញសច្ចធម៌នៅពេលហ្នឹង ឧក្រិដ្ឋកម្មរបស់ខ្ញុំទៅលើជីវិតមនុស្សប៉ុន្មាននាក់? បើកភ្នែកទាំងអស់គ្នា យើងរកការពិត ។ ខ្ញុំអត់តថ្លៃទេ នឹងការពិត ខ្ញុំអត់តថ្លៃទេនឹងជីវិតមនុស្សដែលបាត់បង់ទៅ ខ្ញុំទទួល ក៏ប៉ុន្តែឃើញឯកសារបែបនេះ ខ្ញុំសូមអធិប្បាយប៉ុណ្ណេះ ។ សូមចប់ ។

[១២:០៥:០៥]

**លោក ការ សាវុត្ថ៖**

សូមអនុញ្ញាតលោកប្រធាន សុំសួរមួយសំណួរទៀត ព្រោះមួយសំណួរទៀតចប់ហើយ ខ្ញុំអត់មានសួរទេ ។

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** ហេតុដូចម្តេចបានគេប្រើពាក្យបន្ថុំយ៉ាងនេះ ម្តងគេថា ដោះលែង ម្តងទៀតគេថារត់ ម៉េចក៏ចូលចិត្តបន្ថុំអីចឹងម្ល៉េះ? សូមលោកពន្យល់មើល យ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! រឿងនេះជាឧបាយកលរបស់ ណាត ទេ នេះខ្ញុំនិយាយតាមការឃើញឯកសារ ហើយវិភាគ ជំនាន់ខ្ញុំនៅ ខ្ញុំបានឃើញឯកសារទាំងអស់នេះទេ ។ ជាពិសេសឯកសារថាភរថាដោះលែងហ្នឹង ។ ខ្ញុំមិនបាច់ឃើញអីច្រើនទេ បើសិនជាឃើញតែឯកសារលេខ D57 Index 003 ហើយនិងឯកសារដែលដើមបណ្តឹងរដ្ឋប្បវេណី E2/56 ដែលគាត់ប្តឹងនោះ ។ យកតែឯក-សារពីរហ្នឹង ទៅបញ្ចូល ហើយរាយការណ៍ជូនមេ ។ ណាត ល្បើកមកទាំងទទឹងទិសហ្នឹង ព្រោះ ណាតបាក់បង្អៀងហើយ ។ ឯកសារថ្ងៃប្រជុំអចិន្ត្រៃយ៍មជ្ឈិមថ្ងៃ១៩ ថ្ងៃ២០ ថ្ងៃ២១ មេសា ១៩៧៦ ជាឧទាហរណ៍ស្រាប់ ។ ណាត ត្រូវគេដកសិទ្ធិមិនឲ្យកាន់កាប់កម្លាំង ដូច្នេះ បានអាឯកសារនេះទៅល្បើកហើយ ។ ដូច្នេះ រឿងនេះវាជាឧបាយកលរបស់ ណាត ទេ ។ ហ្នឹងហើយដែលមេខ្ញុំចេះតែនិយាយនៅពេលដែល ណាត ចេញទៅថា ណាត សំបូរល្បិចៗ ។ មិនដឹងជាល្បិចអី ហើយមិនដឹងជាគាត់ក្តាប់ប៉ុន្មានបានទេ ។ ឥឡូវនេះ ឯកសារវាឃើញហើយ គាត់សំបូរល្បិចអ៊ីចឹងមែន ។ ហើយគ្នាខាងក្រោយរត់តាមតែគាត់ ម៉ម ណៃ ខំសរសេរ សូមអង្គការមេត្តាអនុគ្រោះដោះលែង ។ មិត្តម៉េង ហ្នឹងរត់ទៅតាមតែគាត់ប្រើទៅ ។ ខ្ញុំក៏សរសេរនឹងគេដែរ សូមអង្គការចាប់អ្នកនេះ សូមអង្គការតាមដានអ្នកនោះ ។

សរុបមក និយាយនេះមិនមែនជារឿងបិទបាំងខ្លួនទេ ក៏ប៉ុន្តែ តាមឯកសារឃើញមក ខ្ញុំមាន និន្នាការមួយវិភាគបែបនេះ ។ នេះជាសេចក្តីវិភាគរបស់ខ្ញុំទេ ដែលសូមលើកជូនអង្គសវនាការនេះ ហើយជាតិប្រជាជនកម្ពុជាលោកយល់ ។ ហ្នឹងខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

[១២:០៧:៤៦]

**ប្រធានអង្គជំនុំ៖**

អស់សំណួរហើយ? ឥឡូវដល់ពេលត្រូវសម្រាកពិសាអាហារថ្ងៃត្រង់ហើយ ។ ហើយសំណួរចុងក្រោយ គឺរបស់មេធាវីការពារក្តីបានអស់ហើយ ។ តាមកាលវិភាគដែលត្រូវគ្រោងនោះ គឺមួយ

រសៀលទៀត នូវអង្គហេតុប្រតិបត្តិការ-- ការបង្កើត និងប្រតិបត្តិការនៃមន្ទីរព្រៃស និង/ឬ ក៏មន្ទីរ ស-២៤ នេះ ។ ឥឡូវនេះ យើងបានចប់មុនកាលវិភាគដែលបានគ្រោងទុក ។

អ៊ីចឹង អង្គជំនុំជម្រះប្រកាសផ្អាកដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅព្រឹកថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ចាប់ពីម៉ោងប្រាំបួនព្រឹកទៅ ។ ហើយក៏សូមជម្រាបជូនដល់ភាគីថា សវនាការដែលយើងធ្វើនៅសប្តាហ៍ក្រោយនោះ គឺស្តាប់នូវសេចក្តីថ្លែងការណ៍របស់អ្នកដែលបានរស់រានមានជីវិតពីមន្ទីរស-២១ ។ ដូច្នេះ ភាគីជ្រាប ហើយនិងសូមអញ្ជើញចូលរួមដំណើរការសវនាការតាមកាលកំណត់នេះ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់ទីនេះនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក ៕

*[សវនាការផ្អាកនៅម៉ោង ១២:១០ នាទី]*